ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់ អគ្គនាយកដ្ឋានពន្ធដារ

GENERAL DEPARTMENT OF TAXATION`S PROCESS OF COLLECTION PUBLIC TAX

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ

# GENERAL DEPARTMENT OF TAXATION`S PROCESS OF COLLECTION PUBLIC TAX

គ្រូណែនាំ៖ ជ្រុន ស្រីម៉ុម

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥
PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**
**ប្រធានបទ៖ ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់**
**អគ្គនាយកដ្ឋានពន្ធដារ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ជ្រុន ស្រីម៉ុម

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយក
មជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករង
មជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ គណនេយ្យនៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យគឺជាជំនាញមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារគណនេយ្យ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារគណនេយ្យករពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារគណនេយ្យ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ដោយក្រុមយើងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណានិងប្រសិទ្ធភាពនៃការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ។ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



ហ៊ី ហ៊ាត
ID: VI22/018



ហ៊ិន ស្រីលាក់
ID: VI22/035



ហ៊ិន ស្រីណយ
ID: VI22/012



ឆន ជីវី
ID: VI22/022



ស្រ៊ិក ស្រីម៉ី
ID: VI22/033

# **សេចក្តីថ្លែងអំណរគុណ**

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

***សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ***

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដាដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះអ្នកគ្រូ **ជួន ស្រីម៉ុម** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

ក្រុមនាងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យនៃសាកលវិទ្យាល័យវ៉ាន់ដា ជំនាន់ទី២២៖ សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ " ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ" នេះគឺជាស្នាដៃរបស់ក្រុមនាងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ.ពុធ..៨កើត. ខែ.កត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស ២៥៦៩

ថ្ងៃទី២៩.. ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**



ហ៊ី ហ៊ាត

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ក្រោយពីបានសិក្សានៅ **សាកលវិទ្យាល័យវ៉ាន់ដា** និងរួមផ្សំជាមួយការសិក្សាស្រាវជ្រាវទាក់ទងទៅនិងអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារផ្តោតទៅលើប្រធានបទ(**ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ**) នាពេលកន្លងមកនេះហើយបានរៀបចំចងក្រងជាសៀវភៅសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះឡើង។ ក្រុមនាងខ្ញុំសូមយោងយកអត្ថន័យខ្លឹមផ្សារនៃសារណាដូចខាងក្រោមៈ

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ ពីប្រធានបទនៃដំណើរការប្រមូលអាករបំភ្លឺសាធារណៈដែលជាប្រភេទពន្ធមួយស្ថិតក្នុងគោលនយោបាយសារពើពន្ធគ្រប់គ្រងដោយអគ្គនាយកដ្ឋានពន្ធដារ។ ការប្រមូលនេះបានផ្តល់ប្រយោជន៍ជាច្រើនដល់ប្រទេសជាតិដូចជា ជួយទប់ស្កាត់ដល់ការនាំចូលនៅប្រភេទទំនិញដែលបំផ្លាញសង្គមក៏ពិតមែនក៏នៅមានចំណុចខ្វះខាតមួយចំនួនផងដែរ ដោយមូលដ្ឋានគិតពន្ធមានកម្រិតទាប ការប្រមូលពន្ធនៅមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយដែលមានឈ្មួញមួយចំនួនតូចអាចគេចវេសពីការបង់ពន្ធបាន។

អាករបំភ្លឺសាធារណៈ ត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ គឺមាត្រា២៣។ ប៉ុន្តែមាត្រា២៣នេះ ត្រូវបានប្តូទៅជាទៅជាមាត្រា២៣ថ្មីដោយការធ្វើវិសោធនកម្ម ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង២០០២ បំពោះតម្លៃសុរាមេរ៉យ និងបារីដែលលក់ក្នុងមណ្ឌលដែនដីខេត្ត-ក្រុងនីមួយៗ។ អាករបំភ្លឺសាធារណៈត្រូវបានកំណត់អត្រា៣%នៅក្នុងឆ្នាំ២០០២ តែក្រោយមកនៅក្នុងឆ្នាំ២០២៣អត្រានៃអាករបំភ្លឺសាធារណៈត្រូវបានប្តូរទៅជា៥% លើការផ្គត់ផ្គង់គ្រប់ដំណាក់កាលទាំងអស់នៅសុរាមេរ៉យ និងបារីក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍ដល់ថវិការថ្នាក់ក្រោមជាតិ សម្រាប់បំភ្លឺនៅព្រះរាជាណាចក្រកម្ពុជា។

តាមការសិក្សាបានធ្វើឱ្យយើងយល់កាន់តែច្បាស់បន្ថែមទៀតអំពីប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ ទស្សនវិស័យ បេសកកម្ម គោលដៅ រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ប្រវត្តិអាករបំភ្លឺសាធារណៈ បុគ្គលិកជាប់អាករ ប្រភេទនៃទំនិញជាប់អាករ វិធីសាស្ត្រនៃការប្រមូល មូលដ្ឋានគិតអាករ ជាពិសេសសារៈសំខាន់និងគោលបំណងនៃការបង្កើតអាករបំភ្លឺសាធារណៈ។ ហើយបច្ចុប្បន្នក៏យើងសង្កេតឃើញ មានការអភិវឌ្ឍច្រើនទៅលើការបំភ្លឺតាមទីសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗនៅក្នុងប្រទេស។ ដែលការអភិវឌ្ឍយ៉ាងឆាប់រហ័សនេះដោយចំណូលពីការប្រមូលពន្ធជាច្រើនប្រភេទនៅក្នុងប្រទេសកម្ពុជា។

# មាតិកា

ទំព័រ

អារម្ភកថា ..... i
រចនាសម្ព័ន្ធ ..... ii
សេចក្ដីថ្លែងអំណាគុណ ..... iii
អំណះអំណាង ..... vi
សេចក្ដីសង្ខេបនៃការស្រាវជ្រាវ ..... v
មាតិកា ..... vi

## ជំពូកទី១
## សេចក្ដីផ្ដើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ១
១.តើអគ្គនាយកដ្ឋានបានកំណត់មូលដ្ឋានគណនាពន្ធទៅលើអាករបំភ្លឺសាធារណៈយ៉ាងដូចម្ដេច?
២.តើអគ្គនាយកដ្ឋានពន្ធដារធ្វើការគ្រប់គ្រងនិងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈបានតាមវិធីណា?
១.៣ គោលបំណងនៃការស្រាវជ្រាវ ..... ២
១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ..... ២
១.៤.១ ទំហំដែនកំណត់ ..... ២
១.៤.២ វិសាលភាពនៃការស្រាវជ្រាវ ..... ២
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ ..... ២
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ..... ២
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៣

## ជំពូកទី២
## ការប្រមូលអាករបំភ្លឺសាធារណៈ

២.១ លក្ខណៈទូទៅនៃការប្រមូលអាករបំភ្លឺសាធារណៈ ..... ៤
២.១.១ និយមន័យនៃការប្រមូលអាករបំភ្លឺសាធារណៈ ..... ៤
២.១.២ ច្បាប់បង្កើតអាករបំភ្លឺសាធារណៈ ..... ៤
២.១.៣ ទ្រឹស្ដីនៃអាករបំភ្លឺសាធារណៈ ..... ៤
២.២ អគ្គនាយកដ្ឋានបានកំណត់មូលដ្ឋានគណនាពន្ធទៅលើអាករបំភ្លឺសាធារណៈ ..... ៥
២.២.១ និយមន័យអាករ ..... ៦

២.២.២ ប្រវត្តិក្រុមហ៊ុន ........................................................................................................ ៨
២.២.៣ ទ្រឹស្តីពាក់ព័ន្ធ ......................................................................................................... ៩
២.៣ នីតិវិធីអគ្គនាយកដ្ឋានពន្ធដារធ្វើការគ្រប់គ្រងនិងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ .................. ១០
២.៣.១ និយមន័យ ............................................................................................................ ១១
២.៣.២ ប្រវត្តិនៃការគ្រប់គ្រងនិងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ ................................ ១១
២.៣.៣ ទ្រឹស្តីពាក់ព័ន្ធ ...................................................................................................... ១២

## ជំពូកទី៣

## ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ

៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ ....................................................................... ១៣
៣.១.១ ប្រវត្តិនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ....................... ១៧
៣.១.២ ទស្សនវិស័យ បេសកកម្ម គុណតម្លៃ ចក្ខុវិស័យ គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ... ១៧
ក.ទស្សនវិស័យ ..................................................................................................... ១៧
ខ.បេសកកម្ម ......................................................................................................... ១៧
គ.គុណតម្លៃ ......................................................................................................... ១៨
ឃ.ចក្ខុវិស័យ ......................................................................................................... ១៨
ង.គោលដៅ ........................................................................................................... ១៨
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី នឹងភារកិច្ច របស់អគ្គនាយកដ្ឋានពន្ធដារ ...................... ១៨
ក. រចនាសម្ព័ន្ធគ្រប់គ្រង ........................................................................................ ១៩
ខ. តួនាទីគណៈគ្រប់គ្រង ........................................................................................ ១៩
៣.២ អគ្គនាយកដ្ឋានបានកំណត់មូលដ្ឋានគណនាពន្ធទៅលើអាករបំភ្លឺសាធារណៈ ........................ ១៩
៣.២.១ ការកំណត់មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ ................................................ ២០
ក.មូលដ្ឋានគិតពន្ធ ................................................................................................. ២១
ខ.អត្រាអាករ .......................................................................................................... ២២
៣.២.២ ការគណនាអាករសម្រាប់បំភ្លឺសាធារណៈ ................................................................ ២៣
៣.៣ ការគ្រប់គ្រង និងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈអគ្គនាយកដ្ឋានពន្ធដារ ......................... ២៣
៣.៣.១ ការបង្កើតអាករបំភ្លឺសាធារណៈ ............................................................................ ២៤
៣.៣.២ ប្រភេទនៃអាករបំភ្លឺសាធារណៈ ............................................................................. ២៤
៣.៣.៣ គោលបំណងនៃអាករបំភ្លឺសាធារណៈ ..................................................................... ២៥
៣.៣.៤ វិធីសាស្ត្រនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ................. ២៥
ក.ការប្រមូលប្រាក់អាករ ......................................................................................... ២៦
ខ.ការទទួលលិខិតប្រកាសពន្ធ ................................................................................. ២៨

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង............................................................................................២៩
៤.២ ការវិភាគលើចំណុចខ្សោយ.........................................................................................៣០

## ជំពូកទី៥
## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន ......................................................................................................៣១
៥.២ ការផ្តល់អនុសាសន៍ ...................................................................................................៣២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្នប្រទេសកម្ពុជា គឺជាប្រទេសមួយដែលកំពុងអភិវឌ្ឍន៍ ក្រោយពីបានជួបនូវសង្គ្រាមជាច្រើនលើករួចមក។ បើគិតដល់សព្វថ្ងៃនេះប្រទេសកម្ពុជាមានប្រជាជនចំនួនសរុបប្រមាណ១៧លាននាក់ដែលគ្រប់គ្រងដោយរបបកម្ពុជាប្រជាធិបតេយ្យសេរីពហុបក្ស។ ម្យ៉ាងទៀតប្រទេសកម្ពុជាមានការរីកចម្រើនដល់សព្វថ្ងៃនេះដោយសារពឹងផ្អែកលើវិស័យមួយចំនួនដូចជា វិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យពាណិជ្ជកម្ម និងវិស័យទេសចរណ៍ជាដើម ដែលជាប្រភពចំណូលដ៏ចម្បង។ ចំណែកឯរាជរដ្ឋាភិបាលយកចិត្តទុកដាក់ដឹកនាំនឹងផ្តោតសំខាន់ទៅលើគោលនយោបាយពីរប្រភេទគឺ គោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុដែលជាកត្តាធ្វើឱ្យប្រទេសកម្ពុជាមានការរីកចម្រើន។

បើយើងក្រឡេកទៅមើលគោលនយោបាយសារពើពន្ធ គឺជាគោលនយោបាយដែលបង្កើតឡើងនិងគ្រប់គ្រងដោយអគ្គនាយកដ្ឋានពន្ធដារ ក្នុងគោលបំណងត្រួតពិនិត្យនិងតាមដាន ប្រភពចំណូល ចំណាយពន្ធ។ ការប្រមូលពន្ធទាំងនេះរួមមាន ពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល ពន្ធអប្បបរមា ពន្ធលើមធ្យោបាយធ្វើដំណើរនិងដឹកជញ្ជូន ពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា ពន្ធកាត់ទុក ពន្ធលើប្រាក់បៀវត្ស ពន្ធលើអចលនទ្រព្យ ពន្ធលើឈ្នួលផ្ទះនិងដី ពន្ធលើស្លាកយីហោ ព្រមទាំងអាករពិសេស អាករបំភ្លឺសាធារណៈ អាករលើការស្នាក់នៅជាដើម។ ពិតប្រាកដណាស់ពន្ធដារបានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកបង្កើនថវិកាជាតិ សម្រាប់បំពេញនូវសេចក្តីត្រូវការនិងចំណាយសាធារណៈដែលកើនឡើងឥតឈប់ឈរពីមួយឆ្នាំទៅមួយឆ្នាំ។ ទោះបីជាការគណនា និងការប្រមូលពន្ធជាការងារស្មុគស្មាញ តែការប្រមូលមិនអាចប្រមូលបានដោយគ្រាន់តែមានច្បាប់ពន្ធដារនោះទេគឺតម្រូវឱ្យមានការយល់ដឹងនិងចូលរួមសហការរបស់អ្នកជាប់ពន្ធទាំងអស់ផងដែរ។ ទើបអាចទទួលបានប្រាក់ចំណូលយ៉ាងពេញលេញ។

យោងតាមហេតុផលខាងលើនេះហើយទើបក្រុមយើងខ្ញុំជ្រើសរើសយកប្រធានបទស្តីពី **«ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ»** យកមកធ្វើការស្រាវជ្រាវស្រាយបំភ្លឺនិងចងក្រងជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាទូទៅប្រភេទពន្ធ និងអ្នកជាប់ពន្ធមានលក្ខណៈផ្សេងៗគ្នា ទៅតាមប្រភេទអាជីវកម្មនីមួយៗដែលធ្វើប្រតិបត្តិការ ហើយក្នុងពេលបច្ចុប្បន្ននេះយើងសង្កេតឃើញថានៅអគ្គនាយកដ្ឋានពន្ធដារមានការបង្កើតនូវអាករជាច្រើនប្រភេទ ដែលកំណត់ឱ្យត្រូវបង់ពន្ធអាករ ក្នុងចំណោមអាករទាំងនោះក៏មានអាករបំភ្លឺសាធារណៈផងដែរ។ ហេតុដូច្នេះទើបក្រុមនាងខ្ញុំលើកជាសំណួរចោទឡើងថា៖

១.តើអគ្គនាយកដ្ឋានពន្ធដារបានកំណត់មូលដ្ឋានគណនាពន្ធទៅលើអាករបំភ្លឺសាធារណៈយ៉ាងដូចម្តេច?

២.តើអគ្គនាយកដ្ឋានពន្ធដារធ្វើការគ្រប់គ្រងនិងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈបានតាមវិធីសាស្រ្តណា?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះ គឺបង្ហាញពីយន្តការនៃការគណនាអាករបំភ្លឺសាធារណៈ និង អត្ថប្រយោជន៍បន្ថែម ឱ្យអ្នកដែលជាប់ពន្ធទាំងអស់ យល់ដឹងច្បាស់ពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការប្រកាសពន្ធ និងមិនបាត់បង់ថវិការដែលជាចំណូលរបស់ជាតិផងដែរ ដោយផ្តោតទៅលើ៖

- ប្រវត្តិនៃអគ្គនាយកដ្ឋានពន្ធដារនៅកម្ពុជា
- គោលនយោបាយ បេសកកម្ម និងទស្សនៈវិស័យរបស់ពន្ធដារ
- រចនាសម្ព័ន្ធរបស់ពន្ធដារ

## ១.៤ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ និងដែនកំណត់

ការសិក្សាស្រាវជ្រាវនេះគឺសិក្សាទៅលើ ដំណើរការនៃការប្រមូលពន្ធអាករបំភ្លឺសាធារណៈរបស់ អគ្គនាយកដ្ឋានពន្ធដារ អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### ១.៤.២ វិសាលភាព

តាមច្បាប់ស្តីពីសារពើពន្ធ ពន្ធត្រូវបានបង្កើតឡើងជាយូរណាស់មកហើយ ដោយមានពេលវេលាកំណត់ ការសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីដំណើរការនៃប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ទើបក្រុមនាងខ្ញុំធ្វើការស្រាវជ្រាវក្នុងឆ្នាំ២០២២-២០២៣ តែប៉ុណ្ណោះ ។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

ការស្រាវជ្រាវត្រូវបានប្រើតាមវិធីសាស្ត្រគុណវិស័យ (Qualitative Methods) ដោយផ្តោតចម្បង ទៅលើការវិភាគទិន្នន័យ និងឯកសារដែលបានមកពីក្រុមហ៊ុន អគ្គនាយកដ្ឋានពន្ធដារ ដែលពាក់ព័ន្ធទៅ និងប្រធានបទ ដើម្បីយកមកវិភាគ និងសិក្សាស្រាវជ្រាវក្នុងគោលបំណងយកមកបញ្ជាក់អំពីប្រសិទ្ធភាព ក្នុងការប្រមូលអាករបំភ្លឺសាធារណៈ។

សម្រាប់សំណួរទី១ ត្រូវបានប្រមូលតាមបែបគុណវិស័យ តាមរយៈទិន្នន័យ និងឯកសារដែល បានមកពីក្រុមហ៊ុន អគ្គនាយកដ្ឋានពន្ធដារ ដើម្បីយកមកបកស្រាយទៅលើការអនុវត្តតាមវិធីសាស្ត្រ និង មានការកំណត់ពន្ធអ្វីខ្លះ ទើបអាចឱ្យមូលដ្ឋានគណនាពន្ធទៅលើអាករបំភ្លឺសាធារណៈដំណើរការទៅបាន យ៉ាងល្អ។

សម្រាប់សំណួរទី២ ត្រូវបានប្រមូលតាមបែបគុណវិស័យ តាមរយៈទិន្នន័យ និងឯកសារដែល បានមកពីក្រុមហ៊ុន អគ្គនាយកដ្ឋានពន្ធដារ ដើម្បីយកមកដោះស្រាយរកវិធីសាស្ត្រនៃការគ្រប់គ្រងនិងការ ប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ ដែលអាចបម្រើដល់តម្រូវការរួមរបស់សង្គមជាតិទាំងមូល ។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវគឺនាំមកនូវភាពរីកចម្រើនដល់និស្សិតជាច្រើន ក្នុងការផ្លាស់ប្តូរពួកគេឱ្យយល់ដឹងពី សកម្មភាពក្នុងសង្គម ការទំនាក់ទំនងនិងប្រតិបត្តិការមួយចំនួននៅក្នុងពេលបច្ចុប្បន្ន ។ សារៈសំខាន់នៃការសិក្សា ស្រាវជ្រាវនេះគឺបានផ្តល់នូវសារៈសំខាន់ដល់យើងខ្ញុំទាំងអស់គ្នាដូចជា៖

សម្រាប់ស្ថាប័ន៖ យល់ដឹងពីការប្រមូលពន្ធ ការគណនាអាករ ដើម្បីងាយស្រួលបំពេញទៅតាមតម្រូវការរបស់អតិថិជន និងការអនុវត្តការងារជាក់ស្តែងនៅក្នុងក្រុមហ៊ុន។

សម្រាប់សង្គម៖ ជាឯកសារជំនួយជួយបណ្តុះគំនិតឱ្យសិស្សនិស្សិត និងអ្នកសិក្សាទាំងឡាយយល់ដឹងនូវទស្សនៈវែងឆ្ងាយក៏ដូចជាយល់ដឹងពីអត្ថប្រយោជន៍នៃការស្រាវជ្រាវ និងទទួលបានចំណេះដឹងបន្ថែមពីឯកសារទាំងនេះសម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយ។

សម្រាប់កម្មសិក្សាការី៖ បង្កើនចំណេះដឹងនិងការយល់ដឹងបន្ថែមដែលផ្សារភ្ជាប់ជាមួយប្រធាន ដែលបានសិក្សា។ ម្យ៉ាងវិញទៀតបង្កើនភាពក្លាហានដល់ក្រុមសិក្សាស្រាវជ្រាវក្នុងការបញ្ចេញមតិផ្សេងៗ និងដឹងពីសកម្មភាព រចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារផងដែរ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវធ្វើឡើងដើម្បីស្វែងយល់ឱ្យដឹងកាន់តែច្បាស់ នៅចំណុចនីមួយៗនិងបានធ្វើឡើងដោយធ្វើការរាប់បញ្ចូលចំណុចដែលមានសេចក្តីផ្តើមនៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវវិធីសាស្ត្រនៃការស្រាវជ្រាវ ទំហំនិងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ និងមានចំណុចជាច្រើនទៀត។ ក្រោយពីបានសិក្សាការស្រាវជ្រាវរួចមកក្រុមយើងខ្ញុំក៏បានបែងចែកជា ៥ ជំពូកដែលរៀបរាប់ដូចខាងក្រោម។

**ជំពូកទី១៖ សេចក្តីផ្តើម** បរិយាយសង្ខេបពីលំនាំបញ្ហា គោលបំណង មូលហេតុនៃការស្រាវជ្រាវចំណោទបញ្ហាដែនកំណត់ និងវិសាលភាព ហេតុផលមួយចំនួនដែលបង្កើតឱ្យមានការសិក្សាស្រាវជ្រាវ។

**ជំពូកទី២៖ រំលឹកទ្រឹស្តី** បង្ហាញពីនិយមន័យ ប្រវត្តទូទៅដែលពាក់ព័ន្ធ និងទ្រឹស្តីរបស់អ្នកប្រាជ្ញដែលពាក់ព័ន្ធនិងការសិក្សាស្រាវជ្រាវ។

**ជំពូកទី៣៖ លទ្ធផលនៃការស្រាវជ្រាវ** បង្ហាញពីស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ គោលនយោបាយ ទស្សនវិស័យ និងបេសកកម្ម គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ។

**ជំពូកទី៤៖ ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ** វិភាគនិងធ្វើការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយ។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍** ការសន្និដ្ឋានទៅលើចំណុចទាំងអស់ ដែលនៅក្នុងអត្ថបទ និងផ្តល់អនុសាសន៍ទៅលើចំណុចដែលមានកង្វះខាតដើម្បីធ្វើការកែលម្អ។

# ជំពូកទី២
# ការប្រមូលអាករបំភ្លឺសាធារណៈ

## ២.១ លក្ខណៈទូទៅនៃអាករបំភ្លឺសាធារណៈ

### ២.១.១ និយមន័យអាករបំភ្លឺសាធារណៈ

**អាករបំភ្លឺសាធារណៈ** គឺជាប្រភេទពន្ធប្រយោល ដែលគិតទៅលើតម្លៃស្រានិងបារី ដែលអ្នកប្រើប្រាស់មានកាតព្វកិច្ចត្រូវបង់ ហើយដែលត្រូវកាត់ទុកដោយអ្នកលក់ ដើម្បីបង់ជូនរដ្ឋជាបន្តនាពេលក្រោយទៀត ។

**អាករបំភ្លឺសាធារណៈ** ត្រូវបានកំណត់តាមអត្រា ៣% លើការផ្គត់ផ្គង់គ្រប់ដំណាក់កាលនូវ សុរាមេរ័យ និងបារី។ អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ផលិតផលទាំងនេះត្រូវទទួលខុសត្រូវក្នុងការ បង់ប្រាក់អាករនេះ ជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមាន ការផ្គត់ផ្គង់។

**អាករបំភ្លឺសាធារណៈ** គឺជាប្រភេទពន្ធប្រយោលដែលគិតទៅលើសុរាមេរ័យ និងបារី ហើយដែលទទួលកាត់ទុកដោយអ្នកផ្គត់ផ្គង់។

### ២.១.២ ប្រវត្តិនៃការបង្កើតអាករបំភ្លឺសាធារណៈ

យោងតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើដោយប្រើរាជក្រមលេខ នរ-រកម-០១៩៩-០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់លោក-លោកស្រី ជាអាជីវករទាំងអស់ដែលធ្វើការផ្គត់ផ្គង់ (លក់ដូរ) សុរាមេរ័យ និងបារី ដែលជាផលិតផលមកពីបរទេស ក៏ដូចជាអតិថិជនដែលជាអ្នកប្រើប្រាស់មុខទំនិញទាំងនេះ សូមមេត្តាជ្រាបថា សុរាមេរ័យ និងបារីទាំងអស់ដែលជាផលិតផលពីបរទេស ត្រូវជាប់អាករសម្រាប់បំភ្លឺសាធារណៈ។

អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវចាប់អនុវត្តពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ១៩៩៩ តទៅ។

បុគ្គលដែលធ្វើការផ្គត់ផ្គង់ សុរាមេរ័យ និងបារី ដែលជាផលិតផលមកពីបរទេស គឺជាបុគ្គលជាប់អាករសម្រាប់បំភ្លឺសាធារណៈ និង ត្រូវទទួលខុសត្រូវប្រមូលប្រាក់អាករពីអតិថិជនរបស់ខ្លួន និងយកប្រាក់អាករនេះមកបង់ពន្ធជូនអង្គភាពពន្ធដារ។

### ២.១.៣ ទ្រឹស្តីនៃអាករបំភ្លឺសាធារណៈ

**អាករបំភ្លឺសាធារណៈ** ត្រូវបានដាក់ឱ្យអនុវត្តដោយប្រកាសរបស់អន្តរក្រសួង(ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ) លេខ សហវ ពដប្រក ចុះថ្ងៃទី៣០ ខែ កក្កដា ឆ្នាំ ១៩៩៩ ។ អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវបានកំណត់តាមអត្រា៥% លើសុរាមេរ័យ ឬថ្នាំជក់ និងត្រូវបង់តែម្តងគត់នៅពេលផ្គត់ផ្គង់ដំបូងបន្ទាប់ពីផលិត ឬនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា។ អ្នកជាប់ពន្ធដែលធ្វើការផ្គត់ផ្គង់ឬនាំចូលផលិតផលទាំងនេះត្រូវទទួលខុសត្រូវក្នុងការបង់ប្រាក់អាករជូនរដ្ឋបាលសារពើពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ នៃខែបន្ទាប់ពីខែដែលមានការផ្គត់ផ្គង់។ អាករបំភ្លឺសាធារណៈ គឺត្រូវបានប្រមូលឡើងជាប្រយោជន៍ថវិកាថ្នាក់ខេត្ត-ក្រុង ទុកសម្រាប់ចំណាយឱ្យសម្រាប់បំភ្លឺសាធារណៈ[1]។

[1]ស្រ៊ាន់ គឹមស្រៀង, ផា ម៉ី, ពិន គឹមស្រឿន, ជោក ស្រីនី, ហ៊ិន មិថុនា.(២០២៣). *ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់២០ វិទ្យាស្ថាន វ៉ាន់ដា.ទំព័រទី៤ដល់ទី៥.ភ្នំពេញ

## ២.២ អគ្គនាយកដ្ឋានបានកំណត់មូលដ្ឋានគណនាពន្ធទៅលើអាករបំភ្លឺសាធារណៈដូចខាងក្រោម៖

### ២.២.១ និយមន័យអគ្គនាយកដ្ឋាន ពន្ធ និងមូលដ្ឋានគណនាពន្ធ

**អគ្គនាយកដ្ឋាន** គឺជាទីចាត់ការដែលគ្រប់គ្រងដោយនាយកដ្ឋានតាមក្រសួងនានា[2]។

**អគ្គនាយកដ្ឋាន** គឺជាអង្គភាពរដ្ឋាភិបាលឬអង្គការមួយដែលមានភារកិច្ចក្នុងការគ្រប់គ្រង និងធ្វើសកម្មភាពជាដើមក្នុងវិស័យជាក់លាក់មួយ។

**ពន្ធ** គឺជាកាតព្វកិច្ចរបស់រូបវន្តបុគ្គល និងនីតិបុគ្គលទាំងអស់ដែលមានចែង ក្នុងក្រិត្យច្បាប់ ត្រូវតែចូលរួមបង់វិភាគទានជូនរដ្ឋ ក្រោមរូបភាពជាការប្រមូលចំណូលជាតិ ដើម្បីឱ្យរដ្ឋាភិបាលធ្វើការបែងចែកចំណូលឡើងវិញសម្រាប់ជាប្រយោជន៍ដល់សង្គមជាតិទាំងមូល មានន័យថារដ្ឋមិនផ្តល់សេវាកម្មទៅឱ្យអ្នកបង់ពន្ធទាំងនោះដោយផ្ទាល់វិញឡើយ ហើយអ្នកមានចំណូលតិចបង់ពន្ធតិច អ្នកមានចំណូលច្រើនបង់ពន្ធច្រើន។

**ពន្ធ** គឺជា ការទូទាត់ប្រាក់ ឬធនធានផ្សេងៗដោយបុគ្គល ឬអង្គភាពទៅកាន់រដ្ឋ ឬអង្គការដែលមានអំណាច ដើម្បីជួយក្នុងការសម្រេចនូវគោលបំណងជាសាធារណៈ ដូចជា ការអភិវឌ្ឍសេដ្ឋកិច្ច, ការអប់រំ, និងសេវាកម្មសាធារណៈផ្សេងៗ។

**ពន្ធ** គឺមិនមែនជាការបង់ប្រាក់ជាសេវាកម្មត្រូវបានផ្តល់វិញទេ ប៉ុន្តែជាការជួយចូលរួមក្នុងការអភិវឌ្ឍប្រទេស។

**ពន្ធ** គឺជាបន្ទុករបស់អ្នកជាប់ពន្ធចំពោះរដ្ឋ និងជាកាតព្វកិច្ចរបស់គ្រប់សមាសភាពដែលកំណត់ដោយច្បាប់។ យោងតាមច្បាប់ស្តីពីពន្ធដាឆ្នាំ១៩៩៧ ពន្ធសំដៅដល់ពន្ធផ្ទាល់ ដែលជាប្រភេទពន្ធប្រមូលយកដោយផ្ទាល់ពីអ្នកជាប់ពន្ធ(TaxPayer) ក្រៅពីពន្ធគយ ឬអាករដែលសំដៅដល់ពន្ធប្រយោលដែលជាប្រភេទនៃការប្រមូលពន្ធ ដោយប្រយោល (មិនបានប្រមូលយកដោយផ្ទាល់ពីអ្នកជាប់ពន្ធ)។ ការប្រមូលពន្ធនេះ គឺជាការយកតាមតម្លៃ ទំនិញ ឬសេវា ហើយអ្នកជាប់ពន្ធគឺជាអ្នកប្រើប្រាស់ចុងក្រោយ។

**ពន្ធ** គឺជាប្រាក់ដែលយើងប្រមូលក្នុងនាមរដ្ឋាភិបាល។

**ពន្ធ** គឺជារូបភាពនៃការបែងចែកឡើងវិញ នូវចំណូលជាតិដែលរដ្ឋាភិបាលបានប្រើប្រាស់ដើម្បីប្រមូលចំណូល មួយផ្នែកពីគ្រប់សមាសភាពសេដ្ឋកិច្ច មានដូចជាក្រុមហ៊ុន សហគ្រាស អាជីវកម្ម និងប្រជាពលរដ្ឋដើម្បីបម្រើឱ្យតម្រូវការរួមរបស់សង្គមជាតិទាំងមូល។

**ពន្ធ** គឺជារូបធាតុនៃការប្រមូលចំណូល ដែលផ្សារភ្ជាប់ជាមួយនឹងសិទ្ធអំណាច នយោបាយរបស់រដ្ឋាភិបាលដែលក្រិត្យច្បាប់ជាកំណត់។

**ពន្ធ** គឺជាការការបង់វិភាគទាន នូវកាតព្វកិច្ចរបស់គ្រប់សមាសភាពសេដ្ឋកិច្ច ដែលរួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ជូនរាជរដ្ឋាភិបាលដែលមានច្បាប់កំណត់។

**ពន្ធ** គឺជាចំណូលចរន្តដ៏សំខាន់របស់រដ្ឋាភិបាល សម្រាប់ធ្វើការទ្រទ្រង់នូវដំណើរការវិស័យសាធារណៈផ្សេងៗ។

[2] សង្គប្ប. (ឆ្នាំ2023). *អគ្គនាយកដ្ឋាន*. Retrieved February, 02 2025, from https://www.sangapac.com/dictionary/a/6752

**ពន្ធ** មានលក្ខណៈបង្ខំហើយមិនសងឱ្យវិញផ្ទាល់ឡើយ ប៉ុន្តែនិងអាចសងឱ្យវិញជាលក្ខណៈរូបភាពប្រយោលទៅតាមគោលនយោបាយប្រទេសនីមួយៗ។ គ្រប់អង្គភាពអាជីវកម្ម សេវាកម្មដែលចំណុះឱ្យគ្រប់សមាសភាពសេដ្ឋកិច្ចត្រូវមានកាតព្វកិច្ចនិងទំនួលខុសត្រូវ ចំពោះមុខច្បាប់ក្នុងការអនុវត្តឱ្យបានគ្រប់គ្រាន់ក្នុងខ្ទង់ពាន់ទាំងឡាយដែលបានកំណត់និងមានសិទ្ធស្មើៗគ្នា ក្នុងការទទួលមកវិញនូវផលប្រយោជន៍ពីរដ្ឋាភិបាលដែលប្រកបដោយយុត្តិធម៌ព្រមទាំងមានភាពងាយស្រួល។

**ពន្ធ** បានឱ្យមានការផ្លាស់ប្តូរកម្មសិទ្ធនៃប្រភេទចំណូលដែលប្រមូល។ ផ្លាស់ប្តូរកម្មសិទ្ធនៃប្រភពចំណូលនេះបានកំណត់ដោយមុខងារគ្រប់គ្រងសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ហើយបានស្តែងឡើងនៅឯកភាពអំពីគោលចរិកផលប្រយោជន៍របស់រដ្ឋជាមួយនិងផលប្រយោជន៍របស់ក្រុមហ៊ុនសេវាកម្ម និងប្រជាជនគ្រប់រូប។ នៅក្នុងខឿនសេដ្ឋកិច្ចទីផ្សារ ដែលសមាសភាពសេដ្ឋកិច្ចច្រើនជាងគោលនយោបាយពន្ធដារត្រូវយកមកប្រើប្រាស់ជាចាំបាច់ ជាទូទៅពន្ធដារបានចាត់ទុកជាឧបករណ៍ហិរញ្ញវត្ថុយ៉ាងមានប្រសិទ្ធភាព នៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ចហិរញ្ញវត្ថុរបស់រដ្ឋាភិបាលដើម្បីអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិ[3]។

**មូលដ្ឋានគិតពន្ធ** គឺជាការរាប់ខ្ទង់ចំណូលដែលចំណុះឱ្យសកម្មភាពអាជីវកម្ម និងសកម្មភាពផ្សេងៗទៀតដែលត្រូវបានចាត់ទុកជាបង្អែកមួយ ដើម្បីគណនាពន្ធអាករផ្សេងៗ ។មូលដ្ឋានគិតពន្ធនេះវាអាស្រ័យទៅតាមប្រភេទពន្ធនីមួយៗដែលច្បាប់កំណត់ ហើយយើងនឹងបង្ហាញលម្អិតទៅតាមប្រភេទពន្ធនីមួយៗនៅក្នុងមេរៀនបន្តបន្ទាប់[4] ។

**មូលដ្ឋានគិតពន្ធ** គឺជាតម្លៃដីគិតតាម តម្លៃនៅលើទីផ្សារ ទៅតាមទីក្រុង និងតាមតំបន់ជនបទនីមួយៗ ដែលវាយតម្លៃគិតជាម៉ែត្រការ៉េ ឬម៉ែត្រក្រឡា កំណត់ដោយគណៈកម្មការវាយតម្លៃដីធ្លីមិនបានប្រើប្រាស់[5]។

**២.២.២ ប្រវត្តិពន្ធ**

**ពន្ធ** គឺជាការគិតថ្លៃផ្នែកហិរញ្ញវត្ថុជាកំហិត ឬពន្ធប្រភេទផ្សេងទៀតដែលដាក់លើអ្នកជាប់ពន្ធ (បុគ្គល ឬនីតិបុគ្គល) ដោយអង្គការរដ្ឋាភិបាលដើម្បីផ្តល់មូលនិធិដល់ការចំណាយរបស់រដ្ឋាភិបាល និងការចំណាយសាធារណៈផ្សេងៗ( តំបន់ក្នុងស្រុក ឬថ្នាក់ជាតិ ) និងការអនុលោមតាមពន្ធសំដៅទៅលើសកម្មភាព គោលនយោបាយ និងអាកប្បកិរិយាបុគ្គលដែលមានគោលបំណងធានាថាអ្នកជាប់ពន្ធកំពុងបង់ពន្ធត្រឹមត្រូវតាមពេលវេលា និងតាមធានាបាននូវប្រាក់ឧបត្ថម្ភពន្ធត្រឹមត្រូវ និងការបន្ធូរបន្ថយពន្ធ។

ការយកពន្ធដែលស្គាល់ជាលើកដំបូងបានកើតឡើង នៅក្នុងប្រទេសអេហ្ស៊ីបបុរាណប្រហែលឆ្នាំ ៣០០០ -២៨០០ មុន គ.ស។ ការខកខានក្នុងការទូទាត់ទាន់ពេលវេលា (មិនអនុលោមតាមច្បាប់) រួមជាមួយនិងការគេចវេស ឬមិនព្រមបង់ពន្ធ ត្រូវផ្តន្ទទោសតាមច្បាប់។ ពន្ធរួមមានពន្ធផ្ទាល់ និងពន្ធប្រយោល ហើយអាចត្រូវបង់ជាប្រាក់ ឬស្មើនឹងកម្លាំងពលកម្មរបស់វា។

ប្រទេសភាគច្រើនមានប្រព័ន្ធពន្ធដារ ដើម្បីទូទាត់សម្រាប់តម្រូវការសាធារណៈ សង្គមរួម ឬតម្រូវការជាតិដែលបានព្រមព្រៀងគ្នា និងសម្រាប់មុខងាររបស់រដ្ឋាភិបាល។ ការយកពន្ធមួយចំនួនគិតជាភាគរយនៃការបង់ពន្ធ

---

[3] ស្រ៉ាន់ គឹមស្រៀង, ផា ម៉ី, ពិន គឹមស្រឿន, ដោក ស្រីវីន, ហ៊ិន មិថុនា.(២០២៣).*ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់២០ វិទ្យាស្ថាន វ៉ាន់ដា.ទំព័រទី១៤.ភ្នំពេញ

[4] KHsearch. ពន្ធ. (2020, January 21). *និយមន័យមូលដ្ឋានគិតពន្ធ*. Retrieved February, 02 2025, from https://www.khsearch.com/qna/28561

[5] KHsearch. ពន្ធ. (2020, March 10). *និយមន័យមូលដ្ឋានគិតពន្ធ*. Retrieved February, 02 2025, from https://www.khsearch.com/qna/30072

លើប្រាក់ចំណូលប្រចាំឆ្នាំផ្ទាល់ខ្លួន ប៉ុន្តែពន្ធលើមាត្រដ្ឋានភាគច្រើនគឺរីកចម្រើនដោយផ្អែកលើជង្គៀបនៃចំនួនប្រាក់ចំណូលប្រចាំឆ្នាំ។ ប្រទេសភាគច្រើនគិតពន្ធលើប្រាក់ចំណូលរបស់បុគ្គលម្នាក់ក៏ដូចជាលើប្រាក់ចំណូលសាជីវកម្មផងដែរ។

ក្នុងន័យសេដ្ឋកិច្ច ពន្ធផ្ទេរទ្រព្យសម្បត្តិពីគ្រួសារ ឬអាជីវកម្មទៅរដ្ឋាភិបាល។ វាមានឥទ្ធិពលលើកំណើតសេដ្ឋកិច្ច និង សុខុមាលភាពសេដ្ឋកិច្ច ដែលអាចត្រូវបានកើនឡើយទាំងពីរ (ត្រូវបានគេស្គាល់ថាជាមេគុណសារពើពន្ធ) ឬថយចុះ (ត្រូវបានគេស្គាល់ថាជាបន្ទុកលើនៃពន្ធ) ។

**ពន្ធ** គឺជាកិច្ចការគោលនយោបាយដែលពិបាកមួយសម្រាប់សហគ្រាសធនមីក្រូ តូច និងមធ្យម ប៉ុន្តែជាបញ្ហាមួយដែលទាមទារឱ្យយកចិត្តទុកដាក់ខ្ពស់។

**ពន្ធ** គឺជាការបង់វិភាគទាន នូវកាតព្វកិច្ចរបស់សមាសភាពសេដ្ឋកិច្ច ដែលរូបវ័ន្តបុគ្គលនិងនីតិបុគ្គល ជូនរដ្ឋាភិបាលដែលមានច្បាប់កំណត់[6]។

**២.២.៣ ទ្រឹស្តីពន្ធ**

ជាការពិតណាស់ការសិក្សា និងយល់ដឹងអំពីព័ត៌មានរបស់ពន្ធអាចនិងធ្វើឱ្យអ្នកសិក្សានិងអ្នកដែរស្វែងយល់អំពីពន្ធ ពិបាកយល់ដឹងអំពីវា បើទោះបីជាពន្ធទាំងនោះត្រូវបានគេយកទៅកែសម្រួលនិងសម្រាយជាច្រើនភាសាយ៉ាងណាក៏ដោយ។ បើយោងតាមឯកសារដែលយើងបានសិក្សាកន្លងមកពន្ធគឺជាកិច្ចការនយោបាយដ៏ពិបាកមួយសម្រាប់សហគ្រាសធុនមីក្រូ ធុនតូច និងមធ្យម ប៉ុន្តែជាបញ្ហាមួយដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់។ យ៉ាងណាមិញសហគ្រាសធុនមីក្រូ តូច និងមធ្យម ទាំងនោះមានការព្រួយបារម្ភជាច្រើនទៅលើបញ្ហាពន្ធទាំងនេះ។ នៅក្នុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ យើងសង្កេតឃើញថា ពន្ធដារជាច្រើនត្រូវបានបង្កើតឡើងនៅកម្ពុជា ដូចជាពន្ធលើប្រាក់បៀវត្ស និងពន្ធលើអចលនទ្រព្យជាដើម។ បើនិយាយតាមលក្ខណៈ សង្គមសាស្រ្តនិងទស្សនវិជ្ជានយោបាយយើងត្រូវបង់ពន្ធ ពីព្រោះនេះគឺជាកាតព្វកិច្ចរបស់យើងគ្រប់គ្នា ក្នុងនាមជាពលរដ្ឋនៃប្រទេសមួយ។

**ពន្ធ** គឺជាចំណូលចរន្តរបស់រដ្ឋ សម្រាប់ធ្វើការទ្រទ្រង់នូវដំណើរការវិស័យសាធារណៈផ្សេងៗ។ នៅកម្ពុជាបច្ចុប្បន្នទាំង១៣ប្រភេទ ដែលតម្រូវឱ្យប្រជាពលរដ្ឋ ឬអ្នកជាប់ពន្ធទាំងអស់ត្រូវធ្វើការបង់ពន្ធជូនរដ្ឋ។ ប្រភេទពន្ធទាំងនោះមាន៖

- ពន្ធលើប្រាក់ចំណេញ
- ពន្ធអប្បបរមា
- ពន្ធកាត់ទុក
- ពន្ធលើប្រាក់បៀវត្ស
- ពន្ធលើឈ្នួលផ្ទះ និងដី
- ពន្ធតែមប្រិ៍
- ពន្ធប៉ាតង់
- ពន្ធប្រថាប់ត្រា

[6] ស្រ៊ាន់ គឹមស្រៀង, ផា ម៉ី, ពិន គឹមស្រឿន, ដោក ស្រីវីន, ហ៊ិន មិថុនា.(២០២៣).*ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់២០ វិទ្យាស្ថាន វ៉ាន់ដា ប្រវត្តិនៃពន្ធទំព័រ១៤និងទំព័រទី១៥.ភ្នំពេញ

- ពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ពន្ធសត្តឃាត
- ពន្ធលើអចលនទ្រព្យ
- ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ។

**១. វិធានទូទៅនៃការគណនាអាករត្រូវបង់**

តាមច្បាប់មាត្រា ២៣ ថ្មីនៃច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០២ អាករបំភ្លឺសាធារណៈត្រូវ បានប្រមូលតាមចំនួន ៣៥ លើតម្លៃសុរាមេរ័យ និងបារី ដែលលក់ក្នុងមជ្ឈមណ្ឌលដែនដីខេត្ត-ក្រុងនីមួយៗ។ ដើម្បីគណនាប្រាក់អាករត្រូវបង់ បុគ្គលជាប់អាករ Taxpayer ត្រូវធ្វើការបែងចែកឱ្យបាន រវាងផលរបរដែលបានមកពីការផ្គត់ផ្គង់សុរាមេរ័យ និងបារី ជាប់អាករ និងផលរបរនិងការផ្គត់ផ្គង់ទំនិញ ឬសេវាដទៃទៀត។ ក្នុងករណីដែលបុគ្គលជាប់អាកររបបម៉ៅការ estimad regieme taxpayer អាចពុះធ្វើការបែងចែកផលរបរបាន មន្ត្រីពន្ធត្រូវការជួបពិភាក្សាជាមួយបុគ្គលជាប់អាករ ដើម្បីកំណត់សមាត្រនៃផលរបរបានមកពីការផ្គត់ផ្គង់ សុរាមេរ័យ និងបារីជាប់អាករ។ សមាត្រនេះត្រូវពិនិត្យ និងសម្រេចដោយប្រធានសាខាពន្ធដារខេត្ត-ក្រុង[7]។

## ២.៣ ការគ្រប់គ្រង និងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ

### ២.៣.១ និយមន័យការគ្រប់គ្រងនិងអាករ

**ការគ្រប់គ្រង** គឺជាដំណើរការនៃការប្រើប្រាស់ធនធាន នៅក្នុងអង្គភាពឱ្យទទួលបានជោគជ័យដល់អង្គភាព ដោយមានការរៀបចំ ការធ្វើផែនការការដឹកនាំ និងការត្រួតពិនិត្យ។ ដើម្បីធ្វើឱ្យស្ថាប័នមួយដំណើរការទៅមុខ និងរីកចម្រើនប្រកបដោយភាពរឹងមាំបាន វាតម្រូវឱ្យស្ថាប័ននោះមានការគ្រប់គ្រងដ៏ត្រឹមត្រូវ[8]។

**ការគ្រប់គ្រង** គឺជាការប្រើប្រាស់ធនធានមនុស្ស និងធនធានផ្សេងៗ ដើម្បីសម្រេចបាននូវគោលបំណងទាំងឡាយ[9]។

**ការគ្រប់គ្រង** គឺជាដំណើរការនៃអង្គការចាត់តាំងមួយដែលមានប្រសិទ្ធិភាព។

**ការគ្រប់គ្រង** គឺជាការទទួលខុសត្រូវមួយដ៏លំបាកវាទាមទារឱ្យអ្នកគ្រប់គ្រងចាំបាច់ត្រូវមានសមត្ថភាពយល់ដឹងខ្ពស់រហ័សរហួនប្រកបដោយភាពប៉ិនប្រសព្វនឹងមានចំណេះដឹងធំទូលាយបើទោះបីជាយ៉ាងនេះក៏ដោយក៏នៅមានអ្នកគ្រប់គ្រងខ្លះទទួលបានជោគជ័យហើយអ្នកគ្រប់គ្រងបរាជ័យផងដែរ[10]។

---

[7] ស្រ៊ាន់ គឹមស្រៀង, ផា ម៉ី, ពិន គឹមស្រឿន, ដោក ស្រីរីន, ហ៊ិន មិថុនា.(២០២៣).*ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់២០ វិទ្យាស្ថាន វ៉ាន់ដា ទំព័រ១៥ដល់១៧.ភ្នំពេញ

[8] Facebook Page. HRTS Consulting. (2024, October 18). *ការគ្រប់គ្រង.* Retrieved February, 05 2025, from https://www.facebook.com/share/p/15CVvfriUi/

[9] SCRIBD. ជុំ សមវាសនា, ផាន់ ចាន់ពៅ, ឈួន ត្រាយ. (ឆ្នាំ២០២៥). *ការគ្រប់គ្រង.* Retrieved February, 05 2025, from https://www.scribd.com/document/475342687/%25E1%259E%25

[10] Clubniset. មិត្តនិស្សិត. (2011, May 31). *ការគ្រប់គ្រង.* Retrieved February, 07 2025, from https://clubniset.wordpress.com/2011/05/31/%E1%9E%93%E1

**ការគ្រប់គ្រង** គឺជាដំណើរការនៃការធ្វើការជាមួយនឹងមនុស្ស និងធនធានដទៃទៀតដើម្បីសម្រេចបាននូវគោលដៅរបស់អង្គភាព។ អ្នកដែលគ្រប់គ្រងខ្លាំងពូកែត្រូវមានសមត្ថភាព និងប្រសិទ្ធភាព។ សមត្ថភាព គឺជាការសម្រេចគោលដៅដោយដឹងថាការចំណាយធនធានដូចជាមនុស្ស ប្រាក់ វត្ថុធាតុដើម និងពេលវេលាតិចបំផុតដែលអាចធ្វើទៅបាន។ ប្រសិទ្ធភាព គឺជាការសម្រេចគោលដៅនៃអង្គភាពដោយមិនគិតពីការចំណាយ។ អ្នកគ្រប់គ្រងទាំងអស់បរាជ័យគឺបណ្តាលមកពីគ្មានសមត្ថភាព និងប្រសិទ្ធភាពនេះឯង[11]។

**អាករ** គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ និងគ្រប់សមាសភាពសេដ្ឋកិច្ច ត្រូវបង់សាច់ប្រាក់ ឬវត្ថុជូនរដ្ឋទៅតាមច្បាប់កំណត់ ដោយប្រយោល តាមការប្រើប្រាស់ទំនិញឬសេវាកម្ម[12]។

**អាករ** គឺជាការរួមចំណែកជាកំហិតចំពោះចំណូលរបស់រដ្ឋ ដែលប្រមូលដោយរដ្ឋាភិបាលលើប្រាក់ចំណូល និងប្រាក់ចំណេញអាជីវកម្មរបស់កម្មករឬបន្ថែមទៅលើថ្លៃដើមនៃទំនិញ សេវាកម្ម និងប្រតិបត្តិការមួយចំនួន។

**អាករ** គឺជាភាពតានតឹង ឬជាតម្រូវការធ្ងន់របស់អង្គភាពដែលត្រូវទទួលរាប់រង។

និយាយឱ្យងាយស្តាប់ អាករ មានន័យថាជាពន្ធប្រយោល ឬបន្ទុកប្រយោល ឬកាតព្វកិច្ចប្រយោលដែលតម្រូវឱ្យបង់ប្រយោលពីអ្នកជាប់ពន្ធ។

**អាករ-ករ** ឬ ក សំ. បា (ន) គំនរ ពួក ក្រុម លោហៈធាតុផ្សេងៗ កំណើនលោហៈធាតុ ឬ កំណើតត្បូងផ្សេងៗ ត្បូង ឬ លោហៈធាតុផ្សេងៗ រ៉ែ កំណប់ទ្រព្យ។ គុ. ល្អលើសលន់ ល្អកន្លង។ ខ្មែរប្រើពាក្យនេះសំដៅសេចក្តីថា« សួ តង្វាយ ជំនូន ប្រាក់ ពន្ធ» សួយអាករ ឬសួយសារអាករ (ម. ព . សួយ)។ នេយ្យទានដែលបុព្វជិតបានមកក៏ហៅអាករដែរ ពីម្សិលមិញលោកគ្រូខ្ញុំនិមន្តទៅទេសនាអាករសន្ទឹក។ ខ្មែរសម័យបុរាណលុះត្រាតែសួយ ឬពន្ធដែលដកហូតយកអំពីពួកអ្នកជីករកក្នុងដី មានអ្នកជីករកត្បូងជាដើម ឬទ្រព្យដែលបានអំពីគាស់កំណប់ឬក៏ត្បូងនិងលោហៈធាតុដែលត្រូវហូតយកពីអ្នកទាំងនោះ បើពុំនោះដែលគេថ្វាយជារាជបណ្ណាការនោះទើបហៅថា អាករ។ បើភ្ជាប់ពីខាងដើមសព្ទដទៃអ.ថ.អាករៈរ៉ៈ ដូចជា អាករក្បួបអណ្តូង ត្បូង អណ្តូងលោហៈធាតុ។ អាករដ្ឋាន ឬ ស្ថានទីដែលមានត្បូង ឬ មានលោហៈធាតុ។ អាករខនិក ឬអាករខនិក (–ខ:--) អ្នក ជីកត្បូង(បើ ស្ត្រី ជា --និការ)។ អាការ វិទ ឬវិទូអ្នកស្គាល់ត្បូងឬអ្នកស្គាល់កន្លែងកើតត្បូង។ល[13]។

### ២.៣.២ ប្រវត្តិនៃការគ្រប់គ្រង និងអាករ

**ការគ្រប់គ្រង** គឺជាដំណើរការនៃការប្រើប្រាស់ធនធាន នៅក្នុងអង្គភាពអោយទទួលបានជោគជ័យដល់អង្គភាព ដោយមានការរៀបចំ ការធ្វើផែនការ ការដឹកនាំ និងការត្រួតពិនិត្យ ។[14]។

**អាករ** (VAT) ជាប្រភេទពន្ធថ្មីមួយ និងជាគំនិតដែលបានបង្កើតឡើងដំបូងដោយឯករាជ្យនៅដើមសតវត្សទី២០ ដោយលោក Wihelm Von Siemens គឺជាអ្នកជំនាញជនជាតិអាល្លឺម៉ង់ក្នុងឆ្នាំ ១៩១៨ ។ ទោះបីជាយ៉ាងណាក៏ដោយ អាករជាវិធីសាស្ត្រគណនេយ្យមួយបែប ដែលវាដូចជាគ្រោងការនៃការយកពន្ធដែល

---

[11] Clubniset. (៣១ ឧសភា ២០១១). *ការគ្រប់គ្រង* : https://clubniset.wordpress.com/2011/05/31/%E1%9E%93%E1

[12] Property Area. សុធារី. (2011, October 25). *និយមន័យអាករ.* Retrieved February, 07 2025, from https://propertyarea.asia/archives/84407

[13] ស្រ៊ាន់ គឹមស្រៀង, ផា ម៉ី, ពិន គឹមស្រឿន, ដោក ស្រីរីន, ហ៊ិន មិថុនា.(២០២៣). *ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់២០ វិទ្យាស្ថាន វ៉ាន់ដាទំព័រ០៤និង០៦. ភ្នំពេញ

[14] Kh search. គ្រប់គ្រង. (2019, May 09). *ប្រវត្តិនៃការគ្រប់គ្រង.* Retrieved February, 10 2025, from https://www.khsearch.com/qna/24819

ត្រូវបានណែនាំជាសាធារណៈដោយលោក Maurice Laure ជានាយកទទួលបន្ទុកពន្ធ នៅដើមឆ្នាំ១៩៥៤ ។ អាករ ជាមធ្យោបាយមួយដែលអាចដោះស្រាយនូវបញ្ហាផ្សេងៗ ដែលបានកើតឡើងក្នុងការអនុវត្តពន្ធចំណូលសរុប និងពន្ធលក់។ ដូច្នេះហើយ អាករក៏ត្រូវបានបញ្ជូនទៅក្នុងពន្ធលើផលិតផល[15]។

**២.៣.៣ ទ្រឹស្តីពាក់ព័ន្ធនៃការគ្រប់គ្រងនិងអាករ**

**ការគ្រប់គ្រង** គឺជាអង្គការចាត់តាំងនិងជាសមូហភាពមួយដែលមនុស្ស និងធនធានទាំងឡាយត្រូវបានសម្របសម្រួលតាមរយៈការបែងចែកពលកម្ម ការអនុវត្តវិទ្យាសាស្ត្របច្ចេកទេស ដើម្បីសម្រេចផែនការឬគោលដៅណាមួយ។

លោក Frederick W. Talor បានកំណត់ច្បាស់លាស់ឱ្យអ្នកគ្រប់គ្រងទាំងអស់គួរតែ៖

- ត្រូវបានបណ្តុះបណ្តាលលើគោលការណ៍វិទ្យាសាស្ត្រ
- ត្រូវសិក្សាកិត្យានុភាពក្នុងការគ្រប់គ្រង
- ត្រូវចេះបែងចែកការងារឱ្យបានច្បាស់លាស់រវាងអ្នកគ្រប់គ្រង និងកម្មករ
- ការជ្រើសរើស និងបណ្តុះបណ្តាលកម្មករទៅតាមជំនាញរបស់ពួកគេ
- មានការលើកទឹកចិត្តល្អ និងជាគំរូល្អដល់កម្មករ
- ត្រួតពិនិត្យនរណាម្នាក់ដោយពុំប្រើប្រាស់អំណាចផ្តាច់ការ

លោក Adam Smith បានយកចិត្តទុកដាក់យ៉ាងខ្លាំងលើការគ្រប់គ្រង(Management)ពោលគឺ៖

- ការរៀបចំជាគម្រោងឱ្យបានម៉ត់ចត់ (Planning)
- ការរៀបចំចាត់ចែង (Oganize)
- ការដឹកនាំ (Leadin)
- ការត្រួតពិនិត្យឱ្យបានត្រឹមត្រូវ (Controlling) ។

ទ្រឹស្តីអ៊ិច (Theory X)

១.អ្នកគ្រប់គ្រងទទួលខុសត្រូវចំពោះការចាត់ចែងកិច្ចការទាំងឡាយនៃសហគ្រាសផលិតកម្ម រួមមានៈ ថវិកា សម្ភារៈ គ្រឿងបរិក្ខារ មនុស្ស គឺជាក្របខ័ណ្ឌផលប្រយោជន៍នៃការសន្សំសំចៃសេដ្ឋកិច្ចតែមួយប៉ុណ្ណោះ។

២. មុខងាររបស់អ្នកគ្រប់គ្រង គឺលើកទឹកចិត្តដល់កម្មករ ដឹកនាំការខិតខំរបស់ពួកគេ ត្រួតពិនិត្យសកម្មភាពរបស់ពួកគេ និងផ្លាស់ប្តូរអាកប្បកិរិយារបស់ពួកគេ ដើម្បីសម្រេចឱ្យត្រូវតាមតម្រូវការរបស់អង្គភាពចាត់ចែង។

៣. បើគ្មានអន្តរាគមន៍សកម្មភាពបែបនេះរបស់អ្នកគ្រប់គ្រងមនុស្សទាំងឡាយអាចប្រែទៅជាអសកម្ម ឬប្រឆាំងតទល់និងតម្រូវការរបស់អង្គភាពចាត់ចែង។

ទ្រឹស្តីវ៉ាយ (Theory Y)

១.អ្នកគ្រប់គ្រងទទួលខុសត្រូវចំពោះការចាត់ចែងកិច្ចការទាំងឡាយនៃសហគ្រាសផលិតរួមមាន ប្រាក់ សម្ភារៈ គ្រឿងបរិក្ខារ មនុស្ស ដើម្បីផលប្រយោជន៍ សេដ្ឋកិច្ច។

[15]ស្រ៊ាន់ គឹមស្រៀង, ផា មុី, ពិន គឹមស្រឿន, ដោក ស្រីរីន, ហ៊ិន មិថុនា.(២០២៣).*ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់២០ វិទ្យាស្ថាន វ៉ាន់ដា.ទំព័រ០៦. ភ្នំពេញ

២.អាស្រ័យដល់មនុស្សទាំងឡាយរមែងត្រូវការការសរសើរ ការលើកទឹកចិត្តគេក៏មានសក្ដានុពលភាពនូវការអភិវឌ្ឍ អាចទទួលយកបាននូវការទទួលខុសត្រូវ និង ឆន្ទៈ ធ្វើការឆ្ពោះទៅរកគោលបំណងនៃអង្គការចាត់ចែងនេះ។

៣.ភារកិច្ច មានសារៈសំខាន់ក្នុងការគ្រប់គ្រងគឺត្រូវរៀបចំលក្ខខណ្ឌនៃអង្គភាព និង វិធីប្រតិបត្តិដើម្បីឱ្យការងារមានដំណើរឆ្ពោះទៅរកគោលដៅរបស់អង្គភាព ក្នុងក្រមខ័ណ្ឌជាមធ្យោបាយដ៏ល្អបំផុតសម្រាប់បុគ្គលសម្រេចគោលបំណងផ្ទាល់ខ្លួនរបស់គេ[16]។

**អាករ** សំដៅដល់ពន្ធប្រយោល ឬ បន្ទុកប្រយោល កាតព្វកិច្ចប្រយោល ដែលតម្រូវឱ្យអ្នកបង់ប្រយោលពីអ្នកជាប់ពន្ធ។ អាករ គឺជាប្រភេទពន្ធប្រយោល ដែលអ្នកជាប់ពន្ធបង់ពន្ធនេះប្រយោលតាមការប្រើប្រាស់ទំនិញនិងសេវា។

**អាករ** កំណត់ទៅលើការចំណាយទិញរបស់អ្នកប្រើប្រាស់ អាករត្រូវប្រមូលពីការប្រកបអាជីវកម្ម និងការនាំចូល។ ការបង់ពន្ធអាករ គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់ស្ថាប័នពាក់ព័ន្ធនានា ចំពោះរដ្ឋដើម្បីរួមចំណែកការពារ និងអភិវឌ្ឍមាតុភូមិ។ អាកររួមមាន អាករបំភ្លឺសាធារណៈ អាករលើតម្លៃបន្ថែម អាករលើការស្នាក់នៅ អាករលើផលរបរ និង អាករពិសេសលើទំនិញ និងសេវាមួយចំនួន[17]។

---

[16] បណ្ណាល័យអ្នក. Kong Chhayleng. (2020, July 26). *ទ្រឹស្ដីពាក់ព័ន្ធនៃការគ្រប់គ្រង*. Retrieved February, 10 2025, from https://www.facebook.com/banalaineak/posts/84-modern-theory-of-management/167329684831908/

[17] ស្រ៊ាន់ គឹមស្រៀង, ផា ម៉ី, ពិន គឹមស្រឿន, ដោក ស្រីវីន, ហ៊ិន មិថុនា.(២០២៣).*ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ.* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់២០ វិទ្យាស្ថាន វ៉ាន់ដា ទំព័រ០៦.ភ្នំពេញ

# ជំពូកទី៣
# ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ ប្រវត្តិអគ្គនាយកដ្ឋានពន្ធដារ




នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥៣ ហើយនាយកដ្ឋានពន្ធដារត្រូវបានលុបបំបាត់ចោលនៅឆ្នាំ១៩៧៥-១៩៧៩ ដោយសារមានការកើតឡើងនូវសង្គ្រាម របបប្រល័យពូជសាសន៍(ប៉ុលពត ឬខ្មែរក្រហម និងបានធ្វើឱ្យប្រជាជនជួបនូវភាពលំបាកការបាត់បង់ជីវិតជាច្រើនអ្នកផងដែរ។ នៅឆ្នាំ១៩៨០ នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងវិញ។ យ៉ាងណាវិញនាយកដ្ឋានពន្ធដារបានដំឡើងទៅជាអគ្គនាយកពន្ធដារនៅឆ្នាំ២០០៨។ ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើងវិញដំបូងនៅឆ្នាំ១៩៨២ ដែលបានអនុវត្តឡើងនៅរាជធានីភ្នំពេញ និងខេត្តចំនួន១០ផ្សេងទៀតដែលគេហៅថា របបម៉ៅការហើយបានគ្រប់គ្រាន់ដោយនាយកដ្ឋានពន្ធដារ។ លើសពីនេះទៅទៀត នាយកដ្ឋានពន្ធដារបានបង្កើតពន្ធមួយចំនួនផ្សេងទៀតដើម្បីអនុវត្ត និងមានការចែកច្បាប់និងមាត្រាយ៉ាងច្បាស់លាស់។ ហើយបានគ្រប់គ្រង់ដោយនាយកដ្ឋានពន្ធដារក្នុងគោល

បំណាងបង្កើតចំណូលថវិកាជាតិសម្រាប់ចំណាយនានាដោយពុំចាំបាច់បោះពុម្ពលុយដែលអាចបង្កឱ្យមានបញ្ហាអតិផរណា។ ជាងនេះទៅទៀតអគ្គនាយកដ្ឋានពន្ធដារក៏បានបង្កើតពន្ធមួយចំនួនផ្សេងទៀតដើម្បីអនុវត្តន៍ និងមានការចែងច្បាប់និងមាត្រាយ៉ាងច្បាស់លាស់។ ពន្ធទាំងនោះរួមមានៈ

- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រមក/០១.៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ចែងអំពីការអនុញ្ញាតឱ្យប្រមូលអាករបំភ្លឺសាធារណៈលើតម្លៃសុរាមេរ៉ៃ និងបារី ដែលជាផលិតផលមកពីបរទេស។
- ពន្ធប៉ាតង់ ត្រូវបានអនុលោមតាមខ្លឹមសារក្រឹត្យច្បាប់លេខ២២ ក្រ.ច ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ១៩៩៤ ស្តីពីពន្ធប៉ាតង់និងមាត្រា ៣៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ១៩៩៥ ដែលប្រកាសដោយព្រះរាជក្រមលេខ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធ។
- ពន្ធលើប្រាក់បៀវត្ស ចាប់ផ្តើមដំបូងគឺ ចេញពីព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ (ច្បាប់ស្តីពីហិរញ្ញវត្ថុ ឆ្នាំ១៩៩៥) តែត្រូវបានធ្វើវិសោធនកម្មដ៏ធំនៅឆ្នាំ១៩៩៧។
- ពន្ធកាត់ទុក ចាប់ផ្តើមគឺចេញពីព្រះរាជក្រមលេខ នស.រកម.០២៩៧ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ (ច្បាប់ស្តីពី ហិរញ្ញវត្ថុ ឆ្នាំ១៩៩៥) តែត្រូវបានធ្វើវិសោធនកម្មដ៏ធំនៅឆ្នាំ១៩៩៧។

ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៩៧ចេញដោយព្រះរាជក្រមនិងអនុក្រឹត្យលេខ ៨៨ អនុក្រ.បក ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

អាករលើតម្លៃបន្ថែមត្រូវបានអនុម័តដោយព្រះរាជក្រមលេខ នស.រកម ០២៩៧ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ តែអនុម័តពិតប្រាកដថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៩ ។

អនុលោមតាមបទប្បញ្ញត្តិនៃមាត្រា៤ និង៦ ថ្មីនៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានធ្វើវិសោធនកម្មដោយមាត្រា ១១នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ ដែលប្រកាសប្រើដោយព្រះរាជក្រមលេខ នស.រកម. ១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ និងប្រកាសលេខ ១៨២០ សហវ.ប្រក ចុះបញ្ជីគណនេយ្យសាមញ្ញ សម្រាប់ជាប់ពន្ធតូច ។

សរុបរួមរបស់អង្គភាពពន្ធដារ

- ១៩៥៣: ត្រូវបានបង្កើតឡើងជានាយកដ្ឋានពន្ធដារ
- ១៩៧៥-១៩៧៩: ពន្ធដារត្រូវលុបបំបាត់ចោលរបបប៉ុលពត
- ១៩៨០: នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងវិញ
- ២០០៨: នាយកដ្ឋានពន្ធដារបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដាដោយសាលាជាតិពន្ធដារ។

បច្ចុប្បន្ននេះគឺពុំមានព័ត៌មានច្បាស់ការណាមួយស្តីពីសាវតា ឬប្រវត្តិពន្ធដារកម្ពុជាក្នុងអំឡុងពេលមុនឆ្នាំ១៩៧៥ នោះទេ ប៉ុន្តែបើយោងតាមការនិយាយតៗគ្នារបស់បុគ្គលមួយចំនួន ដែលធ្លាប់មានការពាក់ពន្ធជាមួយពន្ធដារកម្ពុជានៅ សម័យកាលទសវត្ស១៩៦០ និង១៩៧០ គឺមុនរបបប្រល័យពូជសាសន៍ ប៉ុល ពត សូមបញ្ជាក់ថា ឯកសារ ឬកំណត់ត្រាប្រវត្តិសាស្ត្រមួយចំនួនរបស់កម្ពុជា ត្រូវបានកម្ទេចចោល ឬបាត់បង់ក្នុងរបបប៉ុល ពត។

បន្ទាប់ពីថ្ងៃរំដោះជាតិមាតុភូមិ ៧ មករា ឆ្នាំ១៩៧៩ ដែលជាថ្ងៃប្រវត្តិសាស្ត្រដ៏ថ្លៃថ្លានៃការរស់រានមានជីវិតឡើងវិញពីរបបប្រល័យពូជសាសន៍ និងជាសម័យកាលដ៏ខ្មៅងងឹតពោពេញដោយសោកនាកម្មដែល

ស្ថានភាព និងហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសទាំងមូលត្រូវលិចលង់ធ្លាក់ចុះដុនដាបក្រោមកម្រិតសូន្យទៅទៀត ដោយសារការកម្ទេច និងរំលាយចោលដោយរបបកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពតហើយដែលប្រជាជន កម្ពុជា និងពិភពទាំងមូលមិនអាចបំភ្លេចបាន។ កម្ពុជានៅពេលនោះ បានចាប់ផ្តើមសាជាថ្មីនូវការខិតខំ ប្រឹងប្រែងកសាង និងស្តារហេដ្ឋារចនាសម្ព័ន្ធប្រទេសជាតិឡើងវិញពីចំណុចក្រោមសូន្យលើគ្រប់វិស័យទាំងអស់ ដោយរាប់ចាប់ពីវិស័យអប់រំ សុខាភិបាល និងសេដ្ឋកិច្ច។ កត្តាអទិភាពចម្បងនីមួយៗរបស់រដ្ឋាភិបាលនៃកម្ពុជា នូវពេលនោះ គឺកាខិតខំបង្កើត និងរក្សាសុខសុវត្ថិភាពជូនប្រទេសជាតិការខិតខំគ្រប់បែបយ៉ាងក្នុងការការពារកុំ ឱ្យមានការវិលត្រឡប់មកវិញនូវរបបប្រល័យពូជសាសន៍ ប៉ុល ពត ក្នុងពេលដែលកម្ពុជាកំពុងខិតខំកសាង និង ស្តារប្រទេសជាតិឡើងវិញ។ នាថ្ងៃទី១២ ខែមករា នៅក្នុងឆ្នាំ១៩៧៩ ប្រជាមានិតកម្ពុជា។ រដ្ឋាភិបាលនៃ សាធារណៈរដ្ឋប្រជាមានិតកម្ពុជាក៏បានបង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងរដ្ឋ ការផ្តល់សេវាសាធារណៈ និងការស្តារ តំបន់ឧស្សាហកម្មសំខាន់ៗសម្រាប់ជម្រុញសកម្មភាពសេដ្ឋកិច្ច។

នៅដើមឆ្នាំ ១៩៨០ ក្រុមប្រឹក្សារដ្ឋនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជាបានដាក់ឱ្យដំណើរការនូវការ ប្រមូលចំណូលថវិការដ្ឋនូវតាមផ្ទះលក់ទំនិញ និងកន្លែងធ្វើអាជីវកម្មធំៗមួយចំនួនតែប៉ុណ្ណោះ ក្រោមរូបភាព ជាការធ្វើវិភាគទាន ដែលជាដែនសមត្ថកិច្ចរបស់អង្គភាព របស់អង្គភាពមន្ទីហិរញ្ញវត្ថុដើម្បីជម្រុញវិស័យសេដ្ឋកិច្ច ឱ្យកាន់តែមានសកម្មភាពផុសផុលបន្ថែមទៀត។

នៅឆ្នាំ ១៩៨១ ក្រុមប្រឹក្សារដ្ឋនៃសាធារណៈប្រជាមានិតកម្ពុជា បានចេញសេចក្តីសម្រេចអនុញ្ញាតឱ្យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុវត្តជាគំរូនូវកិច្ចប្រតិបត្តិការ ចុះឈ្មោះអាជីវកម្មប្រមូលពន្ធអាជីវកម្ម និងពន្ធ លើទំនិញនាំចូលចំពោះមូលដ្ឋានមួយចំនួនតាមរយៈលិខិតលេខ ៧៨ ស.រ.ច ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ១៩៨១។ ផ្អែកតាមខ្លឹមសារនៃសារាចរលេខ ២៤៩-៨១ កហវ.ពដ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៨១ ការអនុវត្តជាគំរូ នេះគឺអនុវត្តតែនៅក្នុងរាជធានីភ្នំពេញ ទីរួមខេត្តកណ្តាល និងស្រុកពញាឮ តែប៉ុណ្ណោះហើយប្រមូលតែ ទៅលើមូលដ្ឋានអាជីវកម្មផ្អែកអាជីវកម្មហូបចុក និងបម្រើការងារដែលកិច្ចការនេះស្ថិតក្រោមដែនសមត្ថកិច្ច របស់នាយកដ្ឋានពន្ធដារឧស្សាហកម្មពាណិជ្ជកម្ម ក្នុងពេលជាបណ្តោះអាសន្នការប្រមូលពន្ធលើមូលដ្ឋាន អាជីវកម្មផ្នែកអាជីវកម្មហូបចុក និងបម្រើការងារគឺអនុវត្តបានតែចំពោះមូលដ្ឋានមួយចំនួន ដែលមានលក្ខណៈ ហ្នឹងព្រមទាំងមានកម្រិតផលរបរមធ្យមប្រចាំខែតាមតារាង ដែលបានកំណត់ពោល គឺមិនទាន់បានធ្វើការ ប្រមូលពន្ធអាជីវកម្មដល់មូលដ្ឋានទាំងឡាយណាដែលលក់ដូរចល័ត ហើយមានផលរបរមធ្យមប្រចាំខែស្ថិត ក្រោមកម្រិតដែលតម្រូវឱ្យបង់ពន្ធ និងបណ្តាមូលដ្ឋានអាជីវកម្មចល័ត ដែលយកផលិតផលកសិកម្មឬសត្វចិញ្ចឹម ដោយផ្ទាល់លក់នៅទីផ្សារ។ ចំពោះផ្នែកផលិតកម្មសិប្បកម្មតូចតាច ផ្នែកសំណង់ដឹកជញ្ជូននេសាទ និងផ្នែក ផ្សេងៗទៀតត្រូវបានដាក់បន្តការសិក្សាស្រាវជ្រាវដើម្បីរៀបចំដាក់អនុវត្តការប្រមូលពន្ធនៅពេលក្រោយ។

នៅចុងឆ្នាំ១៩៨២ ជាជំហានបន្ទាប់ក្រុមប្រឹក្សារដ្ឋនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា បានដាក់អនុវត្តឱ្យ ប្រមូលពន្ធកាន់តែទូលំទូលាយក្នុងក្របខណ្ឌទូទាំងប្រទេសលើកលែងតែខេត្តព្រះវិហារ ខេត្តមណ្ឌលគិរី និងខេត្ត រតនគិរី តាមរយៈក្រឹត្យច្បាប់លេខ ១៤ ក្រ.ច ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៨២។ បន្ទាប់មកក្រសួងហិរញ្ញវត្ថុបាន ដាក់អនុវត្តប្រកាសលេខ២១៤៩-៨២ កហវ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៨២ ស្តីពីការណែនាំអនុក្រឹត្យ-ច្បាប់ពន្ធ អាជីវកម្មហូបចុក និងបម្រើការងារដែលកំពុងមានសកម្មភាពក្រោមរូបភាពឯកជន ឬសមូហភាពដូចជាក្រុមហ៊ុន សមាគម ក្រុមសាមគ្គី សហករណ៍ ក្រុមហ៊ុនចម្រុះជាដើម។ ចំពោះរបៀបរបបនៃការកំណត់ពន្ធសម្រាប់ការ

ប្រមូលពន្ធនេះ គឺមិនគិតតាមអត្រាទេ ប៉ុន្តែត្រូវគិតតាមផលរបរប្រចាំខែ និងកំណត់ប្រាក់ពន្ធត្រូវបង់តែម្តង មានន័យថា បើផលរបរប្រចាំខែតិចគឺបង់ពន្ធតិច បើផលរបរច្រើនគឺបង់ពន្ធច្រើន។ រហូតដល់ឆ្នាំ១៩៩០ នាយកដ្ឋានពន្ធដារឧស្សាហពាណិជ្ជ បានប្តូរឈ្មោះមកជានាយកដ្ឋានពន្ធដារ ហើយនៅតាមបណ្តាខេត្ត-រាជធានី ក្រឹត្យលេខ ២៨ អណក្រ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩០។ ក្រោយពីការបោះឆ្នោតជាសកលបានដាក់អនុវត្ត ដោយកំណត់នូវមូលដ្ឋានសម្រាប់ការប្រមូលពន្ធចាប់ពីឆ្នាំ ១៩៩៨ រហូតមក។

- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១.៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ១៩៩៨ ចែងអំពីការអនុញ្ញាតឱ្យប្រមូលអាករបំភ្លឺសាធារណៈលើតម្លៃសុរាមេរ័យ និងបារីដែលជាផលិតមកពីបរទេស។
- ពន្ធប៉ាតង់ត្រូវបានអនុលោមតាមខ្លឹមសារក្រឹត្យច្បាប់លេខ ២២ ក្រ.ច ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ១៩៩៤ ស្តីពីពន្ធប៉ាតង់ និងមាត្រា ៣៩ នៃច្បាប់ស្តីពីហិរញ្ញវត្ថុការគ្រប់គ្រង ឆ្នាំ ១៩៩៥ ដែលប្រកាសដោយព្រះរាជក្រមលេខ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងបទបញ្ញត្តិស្តីពីសារពើពន្ធ។
- ពន្ធលើបៀរត្សូ ចាប់ផ្តើមដំបូងគឺចេញពីព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ (ច្បាប់ស្តីហិរញ្ញវត្ថុឆ្នាំ ១៩៩៥) តែត្រូវបានធ្វើវិសោធនកម្មដ៏ធំនៅឆ្នាំ ១៩៩៧ ។
- ពន្ធកាត់ទុកចាប់ផ្តើមគឺចេញព្រះរាជក្រមលេខ នស.រកម.០២៩៧ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ (ច្បាប់ស្តីពី ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥) តែត្រូវបានធ្វើវិសោធនកម្មដ៏ធំនៅឆ្នាំ ១៩៩៧ ។
- ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ១៩៩៧ ចេញដោយព្រះរាជក្រម និងអនុក្រឹត្យលេខ ៨៨ អនុក្រ.បក ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តច្បាប់ស្តីវិនិយោគនៃព្រះរាជណាចក្រកម្ពុជា ។
- អាករលើតម្លៃបន្ថែមត្រូវបានអនុម័តដោយព្រះរាជក្រមលេខ នស.រកម ០២៩៧ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ តែអនុម័តពិតប្រាកដគឺ ថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៧ ។
- អនុលោមតាមបទបញ្ញត្តិនៃមាត្រា ៤ និង ៦ ថ្មីនៃច្បាប់សារពើពន្ធដែលត្រូវបានធ្វើសោធនកម្មដោយមាត្រា ១១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦ ប្រកាសប្រើដោយព្រះរាជក្រមលេខ នស.រកម.១២១៥/០១៦ ចុះថ្ងៃទី ១៧ ធ្នូ ឆ្នាំ ២០១៥ និងប្រកាសលេខ១៨២០ សហហវ.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពីការកំណត់វិធាន និងនិតិវិធីនៃការអនុបញ្ជីគណនេយ្យសាមញ្ញរបស់អ្នកជាប់ពន្ធតូច។

នៅក្នុងឆ្នាំ ២០០០ នាយកដ្ឋានពន្ធដារត្រូវបង្កើតឡើងស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំ ២០០៤ ឯកឧត្តម ស៊ុម អៀង ត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានពន្ធដារ បន្ទាប់ពី ឯកឧត្តម ហុង ថា។

ក្នុងឆ្នាំ ២០០៨ នាយកដ្ឋានពន្ធដារត្រូវបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារដែលមានភារកិច្ចគ្រប់គ្រងរដ្ឋបាលប្រមូលពន្ធក្នុងស្រុក (ពន្ធផ្ទៃក្នុង) បង្កើតគោលនយោបាយពន្ធដារក៏ដូចជាធ្វើសេចក្តីព្រៀងច្បាប់ និងបទបញ្ញត្តិពាក់ពន្ធនិងការយកពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយមានការកែសម្រួល និងបង្កើតការិយាល័យបន្ថែមមួយចំនួនទៀត ដើម្បីសម្រួលដល់ការងារប្រមូលចំណូលពន្ធ

តាមរយៈអនុក្រឹត្យលេខ ១៣៤ អន.ក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ដើម្បីឆ្លើយតប និងសម្របទៅតាមការវិវត្ត និងការបន្តរីកធំឡើង ជាបន្តបន្ទាប់នៃវិសាលភាពប្រត្តិបត្តិការរបស់អគ្គនាយកដ្ឋានពន្ធដារទាំងមូល។ ក្រោយពីនាយកដ្ឋានពន្ធដារត្រូវបានដំឡើងទៅជា អគ្គនាយកដ្ឋានពន្ធដារក្នុងឆ្នាំ ២០០៨ ឯកឧត្តមត្រូវបានត្រាស់បង្គាប់តែងតាំងជា ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដាររហូតមកដល់ឆ្នាំ ២០១២ ។

នៅក្នុងឆ្នាំ ២០១២ នេះផងដែរ ឯកឧត្តមក៏ត្រូវបានត្រាស់បង្គាប់តែងតាំងជាអនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាឋានៈស្មើរដ្ឋេធិការ។ ចាប់ពីឆ្នាំ ២០១៣ មកដល់បច្ចុប្បន្នឯកឧត្តម ស៊ុម អៀង ជាទីប្រឹក្សាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ២៨។ នៅក្នុងខែសីហា ឆ្នាំ ២០១២ ខ្លង់ វិបុល ត្រូវបានតែងតាំងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារដោយព្រះរាជក្រិត្យលេខ នស/រកត/០៨១២/៧៣៨ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១២។ ក្នុងឆ្នាំ ២០១៣ អគ្គនាយកដ្ឋានពន្ធដារត្រូវបានកែសម្រួលនិងរៀបចំរចនាសម្ព័ន្ធបន្ថែមទៀតតាមរយៈអនុក្រិត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ដើម្បីឆ្លើយតបទៅនិងតម្រូវការការងារជាក់ស្តែងឱ្យកាន់តែមានប្រសិទ្ធភាព ដោយបានកំណត់បញ្ជាក់យ៉ាងច្បាស់ថា "អគ្គនាយកដ្ឋានពន្ធដារគឺជារដ្ឋបាលសារពើពន្ធដែលមានប្រព័ន្ធចាត់តាំងឯកភាពទទួលខុសត្រូវគ្រប់គ្រងទូទាំងប្រទេស និងត្រួតការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ" ។

### ៣.១.២ ទស្សនវិស័យ បេសកម្ម គុណតម្លៃ ចក្ខុវិស័យ គោលដៅ របស់អគ្គនាយកដ្ឋានពន្ធដារ

**ក.ទស្សនវិស័យ**

អគ្គនាយកដ្ឋានពន្ធដារ ជាអង្គភាពសាធារណៈដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។

**ខ.បេសកកម្ម**

អគ្គនាយកដ្ឋានពន្ធដារ ផ្តល់នូវសេវាដែលមានគុណភាព និងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារប្រកបដោយភាពសុចរិត និងស្មើភាពចំពោះអ្នកជាប់ពន្ធទាំងអស់ ដើម្បីជំរុញអនុលោមភាពដោយស្ម័គ្រចិត្តឈានទៅសម្រេចបាននូវការអភិវឌ្ឍ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

**គ.គុណតម្លៃ**

អគ្គនាយកដ្ឋានពន្ធដារ បំពេញបេសកកម្ម និងធ្វើប្រតិបត្តិការរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវគុណតម្លៃ ដូចខាងក្រោម៖

- ការអនុវត្ត ៖ អនុវត្តវិធាននៃច្បាប់ គាំទ្រប្រជាពលរដ្ឋដែលប្រព្រឹត្តត្រឹមត្រូវ តាមច្បាប់ និងតឹងរ៉ឹងចំពោះជនដែលមិនអនុលោមតាមច្បាប់
- វិជ្ជាជីវៈ ៖ ប្តេជ្ញាចិត្តប្រើវិជ្ជាជីវៈ និងជំនាញ ដើម្បីផ្តល់នូវសេវាដែលមាន ភាពសាមញ្ញ និងងាយស្រួល
- ស័ក្តិសិទ្ធិភាព ៖ ប្រើប្រាស់ធនធានឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព
- សុចរិតភាព ៖ ផ្តល់សេវាឱ្យប្រជាពលរដ្ឋដោយស្មើភាព និងតម្លាភាព
- គារវភាព ៖ ផ្តល់សេវាឱ្យប្រជាពលរដ្ឋប្រកបដោយភាពថ្លៃថ្នូរ និងការគោរព

- ភាពបត់បែន ៖ ឆ្លើយតបយ៉ាងសកម្មទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ពីគ្រប់ឱកាសដែលមាន។

**ឃ. ចក្ខុវិស័យ**

អគ្គនាយកដ្ឋានពន្ធដារ បានបំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានចក្ខុវិស័យជាអង្គភាពមួយត្រូវបានទទួលស្គាល់ គោរព និងជឿទុកចិត្តលើគុណភាព និងជំនាញក្នុងការប្រមូលពន្ធហើយនាពេលអនាគតអគ្គនាយកដ្ឋានពន្ធដារមានចក្ខុវិស័យក្នុងការធ្វើឱ្យនូវការទទួលស្គាល់ និងការគោរពពីសំណាក់អ្នកជាប់ពន្ធចំពោះភាពត្រឹមត្រូវ និងគុណភាពនៃការគ្រប់គ្រង។

**ង.គោលដៅ**

អគ្គនាយកដ្ឋានពន្ធដារ បានកំណត់គោលដៅដូចខាងក្រោម៖

- រៀបចំទស្សនវិស័យ បេសកកម្ម ភារកិច្ច និងរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ
- រៀបចំមុខងារនិងភារកិច្ចរបស់អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់អង្គនាយកដ្ឋានពន្ធដារដើម្បីជានាគុណភព និងប្រសិទ្ធភាពនៃការបំពេញការងារពាក់ព័ន្ធនិងពន្ធដារ។

### ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ

ក. រចនាសម្ព័ន្ធគ្រប់គ្រង



- ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអគ្គនាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ
- ឯកឧត្តម **អ៊ុំ សីហា** អគ្គនាយករង
- ឯកឧត្តម **ដាប ដាវុធ** អគ្គនាយករង
- ឯកឧត្តម **វ៉ាន ពុទ្ធិពល** អគ្គនាយករង
- ឯកឧត្តម **មិញ បានកុសល** អគ្គនាយករង
- ឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករង
- ឯកឧត្តម **ហេង សុខណាង** អគ្គនាយករង
- លោកជំទាវ **ម៉ុន នារី** អគ្គនាយិការង។

ខ. តួនាទី និងភារកិច្ច

- រៀបចំគោលនយោបាយសារពើពន្ធ និងការប្រមូលពន្ធគ្រប់ប្រភេទបង់ចូលថវិការជាតិ
- រៀបចំសេចក្តីព្រាងច្បាប់លិខិតបទដ្ឋាននានាស្តីពីពន្ធដារកំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- កំណត់មូលដ្ឋានគិតពន្ធលើអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ងារដោយផ្អែកលើការសង្កេត និងផ្តុំព័ត៌មាន
- គណនា និងប្រមូលប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងចំណូលផ្សេងៗ
- កសាងកម្មវិធី និងអនុវត្តន៍ការងារសវនកម្មចំពោះអ្នកជាប់ពន្ធ
- ទទួលបន្ទុកសហប្រតិបត្តិការអន្តរជាតិក្នុងផ្នែកពន្ធដារ
- អនុវត្តទោសទណ្ឌតាមច្បាប់អ្នកជាប់ពន្ធ និងភ្នាក់ងារកាត់ទុកដែលល្មើសបទប្បញ្ញត្តិនានាស្តីពីពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិការជាតិប្រចាំឆ្នាំដើម្បីបញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ។

## ៣.២ ការកំណត់មូលដ្ឋានគណនាពន្ធទៅលើអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋាន

### ៣.២.១ ការកំណត់មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ

ដើម្បីគណនាអាករត្រូវបង់ បុគ្គលជាប់អាករត្រូវធ្វើការបែងចែកឱ្យបានវាងផលរបរដែលបានមកពីការផ្គត់ផ្គង់សុរាមេរ័យ និងបារីជាប់អាករ និងផលរបរដែលបានមកពីការផ្គត់ផ្គង់ទំនិញ ឬសេវាដទៃទៀត។ មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈត្រូវបានកំណត់មូលដ្ឋានគិតអាករដូចខាងក្រោម៖

១. ចំពោះអ្នកផលិត និងអ្នកនាំចូលមូលដ្ឋានគិតអាករគឺ ជាថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានាលើកលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង។

| |
|---|
| សម្រាប់វិក្កយបត្រអាករ-អ្នកផលិត និងអ្នកនាំចូល<br>មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ=តម្លៃសរុបលើវិក្កយបត្រមិនរួមអាករ+ អាករពិសេស |
| សម្រាប់វិក្កយបត្រធម្មតា<br>មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ=តម្លៃសរុបលើវិក្កយបត្រមិនរួមអាករ ៖ អតប ៖ អាករបំភ្លឺសាធារណៈខ្លួនឯង |
| អាករបំភ្លឺសាធារណៈ = មូលដ្ឋានគិតអាករ×អត្រាអាករ |

២. ចំពោះអ្នកផ្គត់ផ្គង់បន្ត មូលដ្ឋានគិតអាករស្មើនិង២០ភាគរយ នៃថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងអាករនានា លើកលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង។

សម្រាប់វិក្កយបត្រអាករ-អ្នកផ្គត់ផ្គង់បន្ត (សេវាកម្សាន្ត)
មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ= (តម្លៃសរុបលើវិក្កយបត្រមិនរួមអាករ+ អាករពិសេស)×២០%

សម្រាប់វិក្កយបត្រអាករ-អ្នកផ្គត់ផ្គង់បន្ត
មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ= តម្លៃសរុបលើវិក្កយបត្រមិនរួមអាករ ×២០%

សម្រាប់វិក្កយបត្រធម្មតា-អ្នកផ្គត់ផ្គង់បន្ត
មូលដ្ឋានគិតអាករបំភ្លឺសាធារណៈ=(តម្លៃសរុបលើវិក្កយបត្ររួមអាករៈ អតប ៖អាករបំភ្លឺសាធារណៈខ្លួនឯង)×២០%

អាករសម្រាប់បំភ្លឺសាធារណៈ= មូលដ្ឋានគិតអាករ × អត្រាអាករ

អាករបំភ្លឺសាធារណៈត្រូវបានប្រមូលតាមអត្រា ៣% ចំពោះការផ្គត់ផ្គង់សុរាមេរ៉ៃ និងបារីនៅក្នុងព្រះរាជាចក្រកម្ពុជា។

**អាករបំភ្លឺសាធារណៈពេលផ្គត់ផ្គង់ទំនិញ ឬសេវាគឺជាពេលដែលៈ**

- អ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រ
- អ្នកផ្គត់ផ្គង់បានចេញវិក្កយបត្រប្រសិនបើអ្នកផ្គត់ផ្គង់ចេញវិក្កយបត្រមុនពេលត្រូវចេញ
- អ្នកផ្គត់ផ្គង់ត្រូវចេញវិក្កយបត្រ អ.ត.ប យ៉ាងយឺតរយៈពេល៧ថ្ងៃក្រោយការបញ្ចូលទំនិញ ឬសេវា ឬការទូទាត់ប្រាក់ក្នុងករណីដែលការទូទាត់ត្រូវបានធ្វើឡើងមុនការបញ្ចូលទំនិញ ឬការបំពេញសេវា
- ការដកប្រើប្រាស់ខ្លួនឯងគឺជាពេលដែលទំនិញត្រូវបានយកមកប្រើប្រាស់ដំបូង
- ក្នុងករណីទំនិញឬសេវាត្រូវបានផ្គត់ផ្គង់ក្នុងលក្ខណៈជាអំណោយពេលផ្គត់ផ្គង់គឺជាពេលដែលទំនិញត្រូវបានប្រគល់ឱ្យ ឬពេលដែលផ្គត់ផ្គង់សេវាត្រូវបានធ្វើរួច។

**ចំពោះអ្នកផលិត ឬអ្នកផ្គត់ផ្គង់**

អ្នកផលិត សំដៅដល់បុគ្គលណាមួយដែលធ្វើសកម្មភាពបំប្លែងវត្ថុធាតុដើម ផ្គុំ តម្លើង វេចខ្ចប់ ប្រកបំពេញឱ្យទៅជាផលិតផលសម្រេច។

អ្នកនាំចូល សំដៅដល់លើបុគ្គលណាមួយដែលធ្វើការនាំចូលដោយខ្លួនឯង ឬដោយបុគ្គលដទៃមកក្នុងដែនគយនៃព្រះរាជាណាចក្រកម្ពុជា។

អ្នកផ្គត់ផ្គង់បន្ត សំដៅដល់បុគ្គលដទៃទៀតក្រៅពីអ្នកផលិត ឬអ្នកនាំចូល ដែលផ្គត់ផ្គង់បន្តនូវផលិតផលជាប់អាករ។

មូលដ្ឋានគិតអាករ គឺជាថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានា លើកលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈ។

**គ.មូលដ្ឋានគិតពន្ធ**

-អាករបំភ្លឺសាធារណៈត្រូវបានកំណត់នូវគ្រប់ដំណាក់កាលផ្គត់ផ្គង់ និងត្រូវអនុវត្តលើតម្លៃផ្គត់ផ្គង់ផលិតផលជាប់អាករ រួមបញ្ចូលទាំងអាករនានា **លើកលែងតែអាករបំភ្លឺសាធារណៈខ្លួនឯង និងអ.ត.ប។**

- បុគ្គលដែលធ្វើការផ្គត់ផ្គង់ស្រា ស្រាបៀ សុរាមេរ័យ... និងបារីគ្រប់ប្រភេទ គឺជាបុគ្គលជាប់អាករបំភ្លឺសាធារណៈ និងត្រូវទទួលបង់ប្រាក់អាករនេះ។

- ត្រូវជាប់អាករនេះផងដែរ ចំពោះការដកយកសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន បុគ្គលិក និងតតិយជន។

***មូលដ្ឋានគិតអាករសម្រាប់បំភ្លឺអាករសាធារណៈត្រូវបានកំណត់ដូចខាងក្រោម៖***

**១. ចំពោះអ្នកផលិត និងអ្នកនាំចូលៈ** គឺមូលដ្ឋានគិតអាករត្រូវផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានា លើកលែងតែអាករលើតម្លៃបន្ថែម (អ.ត.ប) និងអាករបំភ្លឺសាធារណៈខ្លួនឯង(អ.ត.ប)។

មូលដ្ឋានគិតអាករ=ផលរបរសរុបលក់បាន- អ.ត.ប- អាករបំភ្លឺសាធារណៈខ្លួនឯង

ឬ មូលដ្ឋានគិតអាករ=( ផលរបរសរុបលក់បាន/1.1/103 )×3%

**⋆អ្នកផលិត**

អាករបំភ្លឺសាធារណៈ=( តម្លៃមិនរួមបញ្ចូលអាករ+អាករលើទំនេញពិសេស )×3% ( គាត់ត្រូវជាប់អាករពិសេសមួយទៀតហើយបានគិតអាករបំភ្លឺសាធារណៈតាមក្រោយ )

**⋆អ្នកនាំចូល**

អាករបំភ្លឺសាធារណៈ=តម្លៃមិនរួមបញ្ចូលអាករ×3% (អ្នកនាំចូលនៅក្នុងវិក្កយបត្រមិនបានគិតអាករពិសេសនោះទេដោយសារនៅពេលគាត់នាំចូលបានបង់ឱ្យទៅអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជារួចហើយ)។

**២. ចំពោះអ្នកផ្គត់ផ្គង់ៈ** មូលដ្ឋានគិតអាករស្មើនឹង ២០ភាគរយ នៃថ្លៃផ្គត់ផ្គង់ដែលត្រូវបានកត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានា លើកលែងតែអាករលើតម្លៃបន្ថែម និងអាករបំភ្លឺសាធារណៈខ្លួនឯង។

មូលដ្ឋានគិតពន្ធ=២០% ថ្លៃផ្គត់ផ្គង់កត់ត្រាវិក្កយបត្រ/១១០% (ដក អ.ត.ប)/១០៣%(ដក អ.ត.ប)

ប្រាក់ពន្ធអាករបំភ្លឺសាធារណៈ=មូលដ្ឋានគិតពន្ធ×៣%

ឬអាករបំភ្លឺសាធារណៈ=តម្លៃមិនរួមបញ្ចូលអាករ×២០%×៣%

☞ **សម្រាប់អ្នកលក់ដំបូង**

មូលដ្ឋានគិតអាករ =ថ្លៃលក់លើវិក្កយបត្រ-អ.ត.ប-អាករបំភ្លឺសាធារណៈ

$= \left(\frac{\text{ថ្លៃលក់លើវិក្កយបត្រ}}{110\%}\right) \div 103\%$

អាករបំភ្លឺសាធារណៈ = មូលដ្ឋានគិតអាករ× 3%

☞ **សម្រាប់អ្នកលក់បន្ត**

មូលដ្ឋានគិតអាករ =( ថ្លៃលក់លើវិក្កយបត្រ-អ.ត.ប-អាករបំភ្លឺសាធារណៈ )× 20%

$=\left[\left(\frac{\text{ថ្លៃលក់លើវិក្កយបត្រ}}{110\%}\right) \div 103\%\right]$

អាករបំភ្លឺសាធារណៈ =មូលដ្ឋានគិតអាករ× 3%

**ខ. អត្រាអាករ**

អាករបំភ្លឺសាធារណៈប្រមូលលើសុរាមេរ៉យ និងបារីបន្ទាប់ពីផលិតនិងនាំចូលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយផ្អែកលើប្រកាសលេខ ៩៧៥ បារី សុរា លក់នៅក្នុងព្រះរាជាណាចក្រកម្ពុជានោះគឺជាកម្មវត្ថុនៃការប្រមូលបំភ្លឺសាធារណៈដើម្បីជាប្រយោជន៍សម្រាប់ការចំណាយសម្រាប់បំភ្លឺសាធារណៈ។

សុរា សំដៅដល់គ្រឿងស្រវឹងគ្រប់ប្រភេទ។

បារី សំដៅដល់បារីគ្រប់ប្រភេទ រួមបញ្ចូលទាំងបារីស៊ីហ្គាផងដែរ។

អាករសម្រាប់បំភ្លឺសាធារណៈមានអាត្រាអាករតែមួយប៉ុណ្ណោះគឺអត្រា៣%។

**៣.២.២ ការគណនាអាករសម្រាប់បំភ្លឺសាធារណៈ**

ប្រកាសលេខ៩៧៦ យកថ្លៃផ្គត់ផ្គង់លើវិក្កយបត្ររួមទាំងអាករពិសេសតែលើកលែងលើអាករលើតម្លៃបន្ថែម និងអាករបំភ្លឺសាធារណៈខ្លួនឯង។

ដើម្បីគណនាអាករបំភ្លឺសាធារណៈត្រូវបែងចែកជា៣គឺៈ

- ការគណនាអាករសម្រាប់សាធារណៈសម្រាប់អ្នកផលិត

| ល.រ Nº | បរិយាយ Description | តម្លៃមិនរួមអាករ Amount exclude tax | អាករពិសេស Specific Tax | អាករ បំភ្លឺ Public for Lighting tax | អតប VAT | ថ្លៃរួមអាករ Amount include tax |
|---|---|---|---|---|---|---|
| | A | B | C=(B+C)*3% | E=(B+C+D)*10% | E=(B+C+D)*10% | F=(B+C+D+E) |
| 1 | ស្រា | 1,000,000 | 315,000 | 39,450 | 135,445 | 1,489,895 |
| 2 | ស្រាបៀ | 1,500,000 | 405,000 | 57,150 | 196,215 | 2,158,365 |
| 3 | បារី | 500,000 | 90,000 | 17,700 | 60,770 | 668,470 |
| សរុបរួម | | 3,000,000 | 810,000 | 114,300 | 311,430 | 4,316,730 |

- ការគណនាអាករសម្រាប់បំភ្លឺសាធារណៈសម្រាប់អ្នកនាំចូល

| ល.រ Nº | បរិយាយ Description | តម្លៃមិនរួមអាករ Amount exclude tax | អាករ បំភ្លឺ Public for Lighting tax | អតប VAT | ថ្លៃរួមអាករ Amount include tax |
|---|---|---|---|---|---|
| | A | B | D=B*3% | E=(B+C)*10% | F=(B+C+D+E) |
| 1 | ស្រា | 1,000,000 | 30,000 | 103,000 | 1,133,000 |
| 2 | ស្រាបៀ | 1,500,000 | 45,000 | 154,500 | 1,699,500 |
| 3 | បារី | 500,000 | 15,000 | 51,500 | 566,500 |
| សរុបរួម | | 3,000,000 | 90,000 | 309,000 | 3,399,000 |

- ការគណនាអាករសម្រាប់បំភ្លឺសាធារណៈសម្រាប់អ្នកចែកចាយបន្ត

| ល.រ Nº | បរិយាយ Description | តម្លៃមិនរួមអាករ Amount exclude tax | អាករ បំភ្លឺ Public for Lighting tax | អតប VAT | ថ្លៃរួមអាករ Amount include tax |
|---|---|---|---|---|---|
| | A | B | D=(B*20%)*3% | E=9B+C)*10% | F=(B+C+D+E) |
| 1 | ស្រា | 1,000,000 | 6,000 | 100,600 | 1,106,600 |
| 2 | ស្រាបៀ | 1,500,000 | 9,000 | 150,900 | 1,659,900 |
| 3 | បារី | 500,000 | 3,000 | 50,300 | 553,300 |
| សរុបរួម | | 3,000,000 | 18,000 | 301,800 | 3,319,800 |

អាករបំភ្លឺសាធារណៈ ត្រូវបានកំណត់នូវគ្រប់ដំណាក់កាលផ្គត់ផ្គង់ និងត្រូវអនុវត្តលើតម្លៃផ្គត់ផ្គង់ផលិតផលជាប់អាករនានា លើកលែងតែអាករបំភ្លឺសាធារណៈខ្លួនឯង និងអាករលើតម្លៃបន្ថែម បុគ្គលដែលធ្វើការផ្គត់ផ្គង់ស្រា ស្រាបៀ សុរាមេរ័យ... និងបារីគ្រប់ប្រភេទ គឺជាបុគ្គលជាប់អាករបំភ្លឺសាធារណៈ និងត្រូវទទួលខុសត្រូវបង់ប្រាក់អាករនេះ ក៏ដូចជាត្រូវជាប់អាករចំពោះការដកយកសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួនបុគ្គលិក និងតតិយជន។ អាករបំភ្លឺសាធារណៈត្រូវបានប្រមូលចំនួន៣% លើតម្លៃសុរាមេរ័យ និងបារីគ្រប់ប្រភេទ។

## ៣.៣ ការគ្រប់គ្រងនិងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ

ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៥៣ បន្ទាប់មកប្រព័ន្ធពន្ធដារត្រូវបានលុបបំបាត់ចោលនៅក្នុងឆ្នាំ១៩៧៥-១៩៧៩ ដោយសារសង្គ្រាម(របបខ្មែរក្រហមនិងប៉ុលពត) ហើយបានធ្វើឱ្យប្រជាជនស្លាប់អស់ជាច្រើននាក់។ ប្រព័ន្ធពន្ធដារបានបង្កើតឡើងវិញនៅដំណាក់កាលដំបូងនៅឆ្នាំ១៩៨០ ដោយបានអនុវត្តនៅរាជធានីភ្នំពេញ និងខេត្តចំនួន១០ផ្សេងទៀត។ លើសពីនេះទៅទៀតអគ្គនាយកដ្ឋានពន្ធដារបានបង្កើតពន្ធមួយចំនួនផ្សេងទៀត ដើម្បីយកមកអនុវត្ត និងមានការបែងចែកច្បាប់ និងមាត្រាយ៉ាងច្បាស់លាស់។ ផ្អែកទៅលើមាត្រាទី៤ នៃច្បាប់សារពើពន្ធបានបង្កើតនូវការកំណត់របបពន្ធជា៣ប្រភេទ៖ គឺរបបពិតរបបម៉ៅការ និងរបបបំព្រួញ ក៏ប៉ុន្តែបទប្បញ្ញត្តិស្តីពីរបបបំព្រួញមានចែងក្នុងក្រដាសមួយដាច់ដោយឡែក។ យ៉ាងណាមិញច្បាប់សារពើពន្ធក៏ជាវិធាននិងជានិតិវិធីដើម្បីចាត់បញ្ចូលអ្នកជាប់ពន្ធឱ្យស្ថិតនៅក្នុងរបបកំណត់ណាមួយនោះ ត្រូវកំណត់ដោយផ្អែកលើទ្រង់ទ្រាយអាជីវកម្ម និងកំរិតផលរបរ។ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះក្នុងប្រទេសកម្ពុជាយើងមានតែរបបពិត(ស្វ័យប្រកាស)តែមួយប៉ុណ្ណោះ។

ការអនុវត្ត និងការកំណត់នៃរបបពិតរបស់សហគ្រាសដោយផ្អែកទៅលើទ្រង់ទ្រាយគតិយុត្តិនៃកម្រិតផលរបរប្រចាំឆ្នាំ និងប្រភេទសកម្មភាពអាជីវកម្ម។

ទ្រង់ទ្រាយគតិយុត្តិមានន័យថា រាល់សហគ្រាសដែលមិនមែនជាសហគ្រាសឯកបុគ្គល គឺត្រូវជាប់ពន្ធរបបពិត ទោះបីសហគ្រាសនោះមានសកម្មភាពអាជីវកម្មប្រភេទអ្វី ឬមានកម្រិតផលរបរប្រចាំឆ្នាំប៉ុន្មានក៏ដោយ។ សហគ្រាសទាំងនោះមានដូចជា សហគ្រាសចម្រុះ ក្រុមហ៊ុនឯកជន សមូហភាពសាធារណៈ ឬអង្គការឯកជនធ្វើសកម្មភាពក្នុងលក្ខខណ្ឌប្រាក់ចំណេញ ឬប្រាក់ចំណូលដែលជាបេតិកភ័ណ្ឌរបស់ខ្លួន។

កម្រិតផលរបរប្រចាំឆ្នាំ គឺជាការកំណត់ពន្ធលើប្រាក់ចំណេញតាមរបបពិតដែលត្រូវអនុវត្ត ហើយចំពោះសហគ្រាសដែលមានផលរបរប្រចាំឆ្នាំចាប់ពី៥០០លានរៀលឡើងទៅ។ ចំណែលឯការផ្គត់ផ្គង់ចម្រុះមានផលរបរប្រចាំឆ្នាំចាប់ពី២៥០លានឡើងទៅ។

រាល់សហគ្រាសដែលធ្វើការដេញថ្លៃ ប្រសិនបើសហគ្រាសទាំងនោះបានទទួលសញ្ញាធ្វើ ឬក៏ជាការផ្គត់ផ្គង់របស់អង្គការសាធារណៈដែលមានចំនួនទឹកប្រាក់ប្រចាំឆ្នាំសរុប ១២៤លានរៀល មានសកម្មភាពដូចជា សណ្ឋាគារ កន្លែងម៉ាស្សា វង្គសាល ភោជនីយដ្ឋាន កន្លែងកម្សាន្តនានាដែលចាត់ថ្នាក់ជាគ្រឹះស្ថានធើត។

### ៣.៣.១. ការបង្កើតអាករបំភ្លឺសាធារណៈ

អាករបំភ្លឺសាធារណៈគឺជាអាករមួយប្រភេទដែលត្រូវកំណត់លើគ្រប់ដំណាក់កាលនៃការផ្គត់ផ្គង់សុរាមេរ័យ(គ្រឿងស្រវឹង) និងបារីក្នុងព្រះរាជាណាចក្រដើម្បីជាប្រយោជន៍ថវិការថ្នាក់ក្រោមជាតិសម្រាប់អាករបំភ្លឺសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា។

ការបង្កើតអាករបំភ្លឺសាធារណៈឡើងគឺ ដើម្បីអនុវត្តនូវគ្រប់ដំណាក់កាលនៃការប្រមូលពន្ធចំពោះសុរាមេរ៍យ(គ្រឿងស្រវឹង) និងបារី។ ចំណែកថវិការដែលប្រមូលបានទុកសម្រាប់ចំណាយអាករបំភ្លឺសាធារណៈ។

**ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនិងអាករបំភ្លឺសាធារណៈ**

- ច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៩
- ប្រកាសអន្តរក្រសួងលេខ១៧៥ សហវ.ពដ.ប្រក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងនៃការប្រមូលអាករបំភ្លឺសាធារណៈ
- ប្រកាសលេខ៩៧៦ សហវ.ប្រក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៧ ស្តីពីការកំណត់មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ។

**៣.៣.២. ប្រភេទនៃអាករបំភ្លឺសាធារណៈ**

អាករសម្រាប់បំភ្លឺសាធារណៈត្រូវបានកំណត់តាមអាត្រា៣% លើការផ្គត់ផ្គង់គ្រប់ដំណាក់កាល លើសុរាមេរ៍យ និងបារី ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍ដល់ថវិការថ្នាក់ក្រោមជាតិ សម្រាប់បំភ្លឺសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា។

ដូច្នេះហើយបានជាអគ្គនាយកដ្ឋានពន្ធដារបានដាក់ច្បាប់យ៉ាងរឹតបន្តឹងទៅលើប្រភេទមុខទំនិញមួយចំនួនដែលត្រូវជាប់អាករបំភ្លឺសាធារណៈរួមមាន៖

- ស្រាបៀ
- ស្រាទំពាំងបាយជូរស្រស់ រួមទាំងស្រាទំពាំងបាយជូរដែលបានបន្ថែមជាតិសុរា
- ស្រាវៀមុត និងស្រាទំពាំងបាយជូរស្រស់ផ្សេងទៀតផ្សំពីរុក្ខជាតិនិងសារជាតិក្រអូប ភេជ្ជៈមេរ៍យផ្សេងទៀតលើកលែងតែទឹកខ្មេះជូរ និងស្រាស
- អាល់កុលអេទិលិកសុទ្ធ ដែលមានកម្រិតជាតិសុរាក្នុងឯកត្តាចំណុះពី៨០%នៃចំណុះនិងភេជ្ជៈមានជាតិសុរា ភេជ្ជៈស្រវឹងផ្សេងៗទៀត ការរៀបចំកែច្នៃសុរាផ្សំក្នុងប្រភេទដែលប្រើសម្រាប់ផលិតភេជ្ជៈបារី និងបារីស៊ីហ្គាគ្រប់ប្រភេទ។

**៣.៣.៣ គោលបំណងនៃអាករបំភ្លឺសាធារណៈ**

ការបង្កើតអាករបំភ្លឺសាធារណៈឡើងមកគឺមានគោលបំណង ប្រមូលពន្ធអាករបំភ្លឺសាធារណៈទៅលើសុរាមេរ៍យ និងបារី។ ដើម្បីយកថវិការទាំងនោះទៅជួយបំពេញនូវរាល់កង្វះខាតសម្រាប់ការចំណាយបំភ្លឺសាធារណៈក៏ដូចជាការចំណាយផ្សេងៗសម្រាប់រដ្ឋក្នុងការអភិវឌ្ឍន៍ប្រទេស។

***គោលបំណងយ៉ាងសំខាន់ក្នុងការប្រមូលអាករបំភ្លឺសាធារណៈគឺ៖***

- សម្រាប់ជាចំណូលថវិការថ្នាក់ក្រោមជាតិ(ថវិការរាជធានី/ខេត្ត) សម្រាប់ចំណាយលើការបំភ្លឺសាធារណៈ។
- អនុវត្តចំពោះការផ្គត់ផ្គង់សុរាមេរ៍យ ឬបារីបន្ទាប់ពីបាននាំចូលឬផលិតក្នុងស្រុកពេលផ្គត់ផ្គង់ទំនិញឬសេវា។
- ដើម្បីទប់ស្កាត់ និងកាត់បន្ថយការប្រើប្រាស់ប្រភេទទំនិញដែលបានលក្ខណៈប៉ះពាល់ដល់សុខភាពប្រភេទទំនិញដែលមិនចាំបាច់ដែលបានការខាតបង់ដល់ប្រយោជន៍ជាតិ។

- ដើម្បីជាប្រយោជន៍ក្នុងការរកចំណូលដល់ថវិការរដ្ឋ។ ពន្ធគឺជាផ្នែកមួយយ៉ាងចម្បងក្នុងចំណូលថវិការជាតិដែលជាធនធានដែលចាំបាច់សម្រាប់ឱ្យរដ្ឋយកទៅអភិវឌ្ឍន៍ក្នុងវិស័យផ្សេងៗដើម្បីកសាងខឿនសេដ្ឋកិច្ចជាតិ។

**៣.៣.៤ វិធីសាស្ត្រនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ**

កាលពីមុនអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ត្រូវធ្វើការបង់ពន្ធ និងស្នើសុំទម្រង់លិខិតប្រកាសពន្ធ នៅតាមសាខាពន្ធដារខណ្ឌរៀងៗខ្លួន។ ប៉ុន្តែដោយមានភាពលំបាកពេកសម្រាប់មន្ត្រីពន្ធដារក៏ដូចជាអ្នកជាប់ពន្ធរាជរដ្ឋាភិបាលកម្ពុជាបានធ្វើកំណែទម្រង់មួយចំនួនដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានការផ្លាស់ប្តូរ នីតិវិធីនៃការប្រមូលពន្ធ អាករ និងការដាក់លិខិតប្រកាសពន្ធផ្សេងឱ្យមានលក្ខណៈទំនើបនិងងាយស្រួលសម្រាប់អ្នកជាប់ពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ក. ការប្រមូលប្រាក់អាករ**

ការប្រមូលប្រាក់អាករ នាពេលបច្ចុប្បន្ន ក៏ដូចជាការប្រមូលប្រាក់ពន្ធដទៃទៀតដែរ គឺអ្នកជាប់ពន្ធទាំងអស់ត្រូវធ្វើការគណនាពន្ធខ្លួនឯង បំពេញលិខិតប្រកាសបង់ពន្ធ ហើយធ្វើការបង់នៅតាមធនាគារដើម្បីផ្តល់សុវត្ថិភាពដល់ថវិការរដ្ឋ។

**ជម្រើសទី១**

ដើម្បីងាយស្រួល និងឆាប់រហ័សទាន់ចិត្ត អ្នកជាប់ពន្ធអាចចូលទៅក្នុងគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ www.tax.gov.kh ដោយថ្លែងរកពាក្យ ការប្រកាសបង់ពន្ធ ហើយអនុវត្តតាមលំដាប់លំដោយ និងការណែនាំនៅក្នុងគេហទំព័រដូចខាងក្រោម៖

- បំពេញការិយបរិច្ឆេទនៃការបង់ពន្ធរបស់ខ្លួន(ខែ ឆ្នាំ ពីថ្ងៃ ដល់ថ្ងៃ) ឧទាហរណ៍៖ ខែកក្កដា ឆ្នាំ២០១៩ ចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី៣១
- ជ្រើសរើសប្រភេទពន្ធនិងបំពេញប្រភេទទឹកប្រាក់ពន្ធដែលត្រូវបង់តាមប្រភេទពន្ធនីមួយៗដូចក្នុងលិខិតប្រកាស
- ជ្រើសរើសកម្រៃសេវាផ្សេងៗ និងបំពេញចំនួនទឹកប្រាក់ដែលត្រូវបង់(ប្រសិនបើមាន)។
- ត្រូវបំពេញចំនួនទំព័រនៃទម្រង់លិខិតប្រកាសនីមួយៗ
- នៅពេលបំពេញរួចត្រូវបោះពុម្ព លិខិតស្នើសុំបង់ប្រាក់ពន្ធចេញពីប្រព័ន្ធគ្រប់គ្រងដែលមាន Barcode សម្រាប់សម្គាល់ចេញពីម៉ាស៊ីនបោះពុម្ព ហើយអ្នកជាប់ពន្ធអាចយកលិខិតនេះទៅបង់ពន្ធ នៅធនាគារណាមួយដែលទទួលបន្ទុកខាងទទួលប្រាក់បង់ពន្ធ។

**ជម្រើសទី២**

ក្នុងករណីអ្នកជាប់ពន្ធមិនសូវចេះប្រើប្រាស់កុំព្យូទ័រ និងប្រព័ន្ធអនឡាញ អ្នកជាប់ពន្ធត្រូវទៅធនាគារណាមួយទទួលបន្ទុកទទួលប្រាក់បង់ពន្ធ ហើយអនុវត្តតាមជំហាននីមួយៗដូចខាងក្រោម៖

- បំពេញទម្រង់បង់ពន្ធ(Form 101) ប្រភេទពន្ធ និងចំនួនទឹកប្រាក់ពន្ធដែលត្រូវបង់ពន្ធតាមប្រភេទពន្ធនីមួយៗនៅក្នុងលិខិតប្រកាស
- ដាក់ទម្រង់បង់ប្រាក់ពន្ធ(Form 101) ដែលបំពេញរួចជូនរដ្ឋមន្ត្រីធនាគារដើម្បីបង់ប្រាក់ពន្ធ។

- ធនាគារចំនួនបីដែលទទួលខុសត្រូវក្នុងការប្រមូលពន្ធជូនរដ្ឋមានដូចជា៖ ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា ក.អ និងធនាគារវឌ្ឍនៈ។

ក្រោយពេលទទួលប្រាក់ពន្ធគ្រប់ចំនួនរួចហើយ ភាគីធនាគារត្រូវបោះពុម្ពបង្កាន់ដៃបញ្ជាក់ការបងប្រាក់ពន្ធការ (Tax Payment Receipt) ចេញពីប្រព័ន្ធគ្រប់គ្រងអគ្គនាយកដ្ឋានពន្ធដារ ដែលមាន៣សន្លឹកគឺ៖ សន្លឹកទី១ ពណ៌ស សម្រាប់មន្ត្រីពន្ធដាររក្សាទុក សន្លឹកទី២ ពណ៌ផ្កាឈូកសម្រាប់ប្រគល់ឱ្យអ្នកជាប់ពន្ធ និង សន្លឹកទី៣ ពណ៌លឿងសម្រាប់ធនាគារ។

លើសពីនេះទៅទៀតតាមរយៈកំណែទម្រង់ថ្មី អគ្គនាយកដ្ឋានពន្ធដារបានផ្តល់នូវសេចក្តីទុកចិត្តដល់សហគ្រាសដែលជាអ្នកជាប់ពន្ធដោយការជូនដំណឹងដោយស្វ័យប្រវត្តិ (Automate and Generate SMS & email) តាមរយៈការផ្ញើសារ ឬតាម E-mail បញ្ជាក់ថាសហគ្រាសនោះបានបង់ប្រាក់ពន្ធ និងកាលបរិច្ឆេទដែលបានចែងក្នុងបង្កាន់ដៃបញ្ជាក់ការទទួលប្រាក់ពន្ធ បើសិនជាអ្នកជាប់ពន្ធដែលជាម្ចាស់សហគ្រាសបានផ្តល់លេខទូរស័ព្ទ និង E-mail មកអគ្គនាយកដ្ឋានឱ្យបានត្រឹមត្រូវ។ ចំណែកឯប្រភេទនីមួយៗនិងប្រាក់សរុប គឺមានលម្អិតនៅក្នុងបង្កាន់ដៃបញ្ជាក់ការទទួលប្រាក់ពន្ធដែលចេញជាផ្លូវការ។

**លំហូរនៃទឹកប្រាក់ពន្ធចូលថវិកាជាតិ**




រូបភាពខាងលើមានអត្ថន័យដូចខាងក្រោម៖

គំនូសបំព្រួញទី១៖ អ្នកជាប់ពន្ធធ្វើការបង់ប្រាក់នូវធនាគារទទួលបន្ទុកប្រមូលប្រាក់ពន្ធនីមួយៗ។

គំនូសបំព្រួញទី២៖ ក្រោយពីទទួលបានការបង់ប្រាក់ពន្ធ-អាករធនាគារធ្វើការផ្ទេរនូវប្រាក់ទាំងអស់ចូលទៅក្នុងរតនាគារជាតិកម្ពុជា ដើម្បីទុកជាថវិការរដ្ឋសម្រាប់ការចំណាយផ្សេងៗ។ ខាងក្រោមនេះគឺជាទិន្នន័យនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងរយៈពេលពីរបីឆ្នាំជាប់គ្នាគិតចាប់ពីឆ្នាំ ២០២២-២០២៣។

| ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|
| ២០២២ | ២០២៣ | ចំនួនទឹកប្រាក់ | ភាគរយ |
| ១៦១,៨៥៩២.០លានរៀល | ២៣៧,៨២០.៨០លានរៀល | ៧៥,៩១១.៦០លានរៀល | ៤៦.៩០% |

**ខ. ការទទួលលិខិតប្រកាសពន្ធ**

ក្រោយពេលបានបង្កាន់ដៃបញ្ជាក់ការទទួលប្រាក់ពន្ធ ហើយអ្នកជាប់ពន្ធត្រូវភ្ជាប់បង្កាន់ដៃនេះ (សន្លឹកទី១៖ ពស សម្រាប់មន្ត្រីពន្ធដារ) ជាមួយលិខិតប្រកាសពន្ធដែលមានចុះហត្ថលេខា និងត្រាត្រឹមត្រូវ ហើយភ្ជាប់មកជាមួយនិងឯកសារដែលពាក់ព័ន្ធនានាមកដាក់ជូនមន្ត្រី ទទួលលិខិតប្រកាសនូវអង្គភាពពន្ធដារទទួលបន្ទុកបន្ទាប់មកមន្ត្រីទទួលលិខិតប្រកាស និងបោះពុម្ពជូនលិខិតបញ្ជាក់ការទទួលលិខិតប្រកាសភ្លាមៗ។

ចំពោះបង្កាន់ដៃទទួលប្រាក់ពន្ធទាំងឡាយណា ដែលខុសពីបង្កាន់ដៃបញ្ជាក់ការទទួលប្រាក់ពន្ធមាននូវក្នុងសេចក្តីណែនាំនេះ អគ្គនាយកដ្ឋានពន្ធដារពុំទទួលស្គាល់ថា សហគ្រាសបានបង់ពន្ធតាមប្រព័ន្ធគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារនោះទេ។

ក្រោយពីទទួលបានលិខិតប្រកាសពន្ធចំនួនបីច្បាប់ពីអ្នកជាប់ពន្ធ មន្ត្រីទទួលលិខិតប្រកាសពន្ធធ្វើការពិនិត្យ ថាតើអ្នកជាប់ពន្ធបានបង់ត្រឹមត្រូវ តាមការបំពេញនៅក្នុងលិខិតប្រកាសពន្ធ និងមានឯកសារយោងច្បាស់លាស់ភ្ជាប់មកជាមួយដែរឬទេ។ ឧទាហរណ៍ សម្រាប់អាករបំភ្លឺសាធារណៈមន្ត្រីពន្ធដារធ្វើការពិនិត្យលើចំណុចមួយចំនួនដូចខាងក្រោមៈ

- ចំនួនទឹកប្រាក់ដែលអ្នកជាប់ពន្ធបង់ទៅធនាគារត្រូវស្មើនិងចំនួននៅក្នុងលិខិតប្រកាស
- ទិនានុប្បវត្តិទិញ លក់ត្រូវតែដូចនៅអ្វីដែរបំពេញក្នុងលិខិតប្រកាស
- វិក្កយបត្រអាករក្នុងករណីអ្នកជាប់ពន្ធស្នើសុំឥណទានអាករលើធាតុចូល
- ហត្ថលេខានិងត្រា ត្រូវមាននៅគ្រប់លិខិតប្រកាស អតប និងទិនានុប្បវត្តិលក់...។

ក្រោយពីបានធ្វើការពិនិត្យរួចរាល់ ហើយបើសិនជាត្រឹមត្រូវដូចចំណុចខាងលើមន្ត្រីទទួលលិខិតប្រកាសធ្វើការចេញនៅលិខិតបញ្ជាក់ ការទទួលលិខិតប្រកាសហើយប្រគល់ឯកសារចំនួនមួយច្បាប់ទៅអ្នកជាប់ពន្ធរក្សាទុក ក៏ដូចជាផ្ញើរសារដោយស្វ័យប្រវត្តិទៅកាន់ម្ចាស់សហគ្រាសថាបានទទួលលិខិតប្រកាសរួចរាល់ហើយ។ ក្នុងករណីដែលមន្ត្រីពន្ធធ្វើការពិនិត្យឃើញថា អ្នកជាប់ពន្ធធ្វើការប្រកាសពន្ធនិងមានភ្ជាប់ឯកសារត្រឹមត្រូវ ឬទឹកប្រាក់បង់ពន្ធខុសពីឯកសារភ្ជាប់មន្ត្រីពន្ធធ្វើការជូនដំណឹងទៅអ្នកជាប់ពន្ធភ្លាមៗឱ្យធ្វើការកែតម្រូវឱ្យបានត្រឹមត្រូវវិញ។ ការចេញលិខិតបញ្ជាក់ ការទទួលលិខិតប្រកាសពន្ធមិនបញ្ជាក់ថាអ្នកជាប់ពន្ធត្រឹមត្រូវនោះទេលុះត្រាតែមន្ត្រីទទួលបន្ទុកធ្វើការពិនិត្យម្តងទៀតតាមរយៈការវាយបញ្ចូលនូវពន្ធ-អាករដែលអ្នកជាប់ពន្ធបានប្រកាសនូវក្នុងប្រព័ន្ធកត់ត្រាពន្ធផ្ទៃក្នុងរបស់ពន្ធដារ( Tax Collction System ) ដែលចង់ក្រងជារូបមន្តនិងគណនាចំនួនទឹកប្រាក់ពន្ធដោយស្វ័យប្រវត្តិ នោះនិងដឹងថាសហគ្រាសណាដែលគណនានិងបង់ពន្ធត្រឹមត្រូវទៅតាមការប្រកាស។

ក្នុងករណីដែលពិនិត្យ និងផ្ទៀងផ្ទាត់ឃើញថាអ្នកជាប់ពន្ធធ្វើការគណនា និងបង់ពន្ធត្រឹមត្រូវតាមការប្រកាស ហើយខាងការិយាល័យចាត់ចែងទទួលលិខិតប្រកាសធ្វើការរក្សាទុកឯកសារមួយច្បាប់សម្រាប់បញ្ជូនទៅអគ្គនាយកដ្ឋានពន្ធដារ និងមួយច្បាប់ទៀតទុកតម្កល់នៅសាខាពន្ធដារខណ្ឌដោយធ្វើការរក្សាទុករយៈពេល១០ឆ្នាំ។ ក្នុងរយៈពេលចុងក្រោយនេះរដ្ឋាភិបាលកម្ពុជាចាប់ផ្តើមរឹតបន្តឹងច្បាប់ពន្ធបន្តិចម្តងៗ។ ជាក់ស្តែងឥឡូវនេះ រដ្ឋាភិបាលបានជំរុញបន្ថែមទៀតឱ្យប្រជាពលរដ្ឋបង់ពន្ធលើប្រាក់ខែ។ អ្នកដែលទទួលបានប្រាក់ខែ ក្នុងចន្លោះពី៣០០ដុល្លារដល់ជាង៣ពាន់ដុល្លារសហរដ្ឋអាមេរិក ត្រូវជាប់កាតព្វកិច្ចបង់ពន្ធក្នុងចន្លោះ៥%ទៅ២០%តែអ្នកដែលទទួលបានប្រាក់បៀវត្សក្រោមពី៣០០ដុល្លារអាមេរិក មិនត្រូវឱ្យបង់ពន្ធឡើយ។

ក្រៅពីការបង់ពន្ធប្រាក់ខែ ប្រជាពលរដ្ឋត្រូវបង់ពន្ធលើអចលនទ្រព្យ ពន្ធលើយានជំនិះ ពន្ធលើប្រាក់បង់ចំណេញ និងពន្ធដារផ្សេងៗទៀត។ ការបង់ពន្ធ គឺរឿងធម្មតាសម្រាប់ប្រទេសជឿនលឿន ប៉ុន្តែសម្រាប់ប្រទេសក្រីក្រកម្ពុជាវិញ ការបង់ពន្ធហាក់បីដូចជារឿងថ្មីហើយពួកគេមិនចង់ចូលរួមបង់ពន្ធទេ។ តើនេះបណ្តាលមកពីហេតុអ្វី?

ការពីពេលមុនរដ្ឋាភិបាលនៃប្រទេសកម្ពុជា ពឹងផ្អែកខ្លាំងទៅលើប្រាក់ចំណូលបានពីពន្ធគយសម្រាប់ការអភិវឌ្ឍជាតិ ប៉ុន្តែដោយសារពន្ធគយត្រូវបានប្រទេសក្នុងតំបន់អាស៊ានព្រមព្រៀងគ្នាកាត់បន្ថយបន្តិចម្តងៗក្នុងចំណោមសមាជិករបស់ខ្លួននោះរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាចាប់ផ្តើមសម្លឹងមើលប្រភពចំណូលផ្សេងក្រៅពីប្រាក់ចំណូលពន្ធគយ។ ប្រាក់ចំណូលដែលរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងសម្លឹង

មើលសម្រាប់បំពេញថវិកាជាតិនាពេលខាងមុខនេះគឺប្រាក់ចំណូលពន្ធដារ។ ចំណូលពន្ធដារគឺជាប្រាក់ចំណូលដែលរដ្ឋាភិបាល ប្រមូលក្នុងប្រទេសដូចជា៖ ពន្ធលើប្រាក់ខែ ពន្ធលើមធ្យោបាយដឹកជញ្ជូន ពន្ធលើប្រាក់ចំណេញ និងលើសេវាកម្មមួយចំនួនផ្សេងទៀត។ អ្វីដែលជាការកត់សម្គាល់ គឺថានៅគ្រាចុងក្រោយនេះរដ្ឋាភិបាលបានជំរុញការប្រមូលពន្ធលើអចលនទ្រព្យ ដីធ្លី ផ្ទះសម្បែង ពន្ធលើយានជំនិះ និងពន្ធលើប្រាក់ខែ។ ប្រភេទពន្ធទាំងនេះមិនថ្មីទេសម្រាប់ប្រទេសជឿនលឿនគោរពច្បាប់ប៉ុន្តែ សម្រាប់ប្រទេសក្រីក្រកម្ពុជាទើបងើបចេញពីសង្គ្រាមប្រភេទពន្ធនេះហាក់បីដូចជាអំរែកថ្មីមួយទៀតសម្រាប់ប្រជាជន។ ហើយពន្ធលើប្រាក់បៀវត្សក៏ជាការដាក់សម្ពាធបន្ថែមបុគ្គលិក កម្មករ និងមន្ត្រីរាជការ។

នៅក្នុងប្រទេសគោរពច្បាប់ការបង់ពន្ធគឺជាកាតព្វកិច្ចមិនអាចគេចវេសបានសម្រាប់ប្រជាពលរដ្ឋគ្រប់រូប។ ប៉ុន្តែសម្រាប់ប្រទេសកម្ពុជាវិញកាតព្វកិច្ចបង់ពន្ធឬពន្ធដារទេនៅមានភាពធូរលុង។ ឈ្មួញមួយចំនួនព្យាយាមមិនបង់ពន្ធក្នុងខណៈពេលដែលឈ្មួញមួយចំនួនទៀតសុខចិត្តបង់ពន្ធតាមការទាមទាររបស់រដ្ឋ។ ចំពោះពន្ធលើប្រាក់ខែ និងពន្ធលើអចនទ្រព្យ ដីធ្លី ផ្ទះសម្បែងគេសង្កេតឃើញថាប្រជាជនមួយចំនួនចាប់ផ្តើមយល់ដឹងពីកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។ ពួកគេខ្នះខ្នែងបំពេញក្រដាសស្នាមខ្លួនឯងហើយយកប្រាក់ទៅបង់ជូនរដ្ឋ។ ប៉ុន្តែប្រជាពលរដ្ឋខ្លះទៀតនៅធ្វើប្រងើយកន្តើយនឹងរឿងនេះនៅឡើយ ដោយភាពប្រងើយកន្តើយនេះហើយដែលមិនមានកើតឡើងដោយសារពួកគេនោះទេ។ តាមពិត គឺដោយសារតែប្រជាជនមួយចំនួននៅចោទជាសំណួរថា តើប្រាក់ដែលបង់ពន្ធជូនរដ្ឋនេះវានៅទីណា ហើយគេយកទៅធ្វើអ្វីឱ្យប្រាកដ? តើការប្រមែប្រមូលពន្ធមានតម្លាភាពដែរឬទេ? ជាធម្មតាការប្រមូលពន្ធមិនថានូវប្រទេសជឿនលឿនគោរពច្បាប់ឬនៅកម្ពុជាទេ គោលការណ៍គឺសម្រាប់បម្រើផលប្រយោជន៍របស់រដ្ឋ មានន័យថាជាមួយនឹងទឹកប្រាក់ពន្ធនេះរដ្ឋាភិបាលត្រូវយកទៅចំណាយសម្រាប់កសាងផ្លូវថ្នល់ សាលារៀន មន្ទីពេទ្យនិងសម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធដទៃទៀត។ ម្យ៉ាងវិញទៀតទឹកប្រាក់មួយចំណែកត្រូវរក្សាទុកសម្រាប់ប្រាក់ចំណូលនិវត្តន៍នៃប្រជាពលរដ្ឋរបស់ខ្លួន។

សម្រាប់ប្រទេសកម្ពុជា ដោយសារតែការបង់ពន្ធជាវប្បធម៌ថ្មី និងដោយសារតែការមិនទុកចិត្តលើសេវារបស់រដ្ឋនោះប្រជាពលរដ្ឋនៅអល់អែក និងចោទជាសំណួរមិនចេះចប់មិនចេះហើយជុំវិញបញ្ហាបង់ពន្ធនេះ។ អ្នកខ្លះបន្តសំណួរថា ប្រសិនបើគេបង់ពន្ធជូនរដ្ឋគ្រប់ប្រភេទទាំងអស់ តើពួកគេអាចទទួលបានអ្វីពីរដ្ឋវិញនូវពេលដែលពួកគេចូលនិវត្តន៍នោះ? ពន្ធចេះតែបង់តែពេលចាស់ទៅរដ្ឋាគ្មានបានគិតគូរអ្វីទាំងអស់។ សម្រាប់មន្ត្រីរាជការរដ្ឋពួកគេអាចទទួលបានប្រាក់ចូលនិវត្តន៍ខ្លះតែចំពោះបុគ្គលិកអង្គការក្រុមហ៊ុនឯកជនវិញតើពួកគេរំពឹងបានអ្វីពីរដ្ឋាភិបាល?

សរុបសេចក្តីមកវិញ ដើម្បីឱ្យប្រជាពលរដ្ឋមានទំនុកចិត្តហើយចូលរួមបង់ពន្ធដើម្បីកសាងប្រទេសជាតិយន្តការនៃការប្រមូលពន្ធត្រូវធ្វើឡើងដោយតម្លាភាពពន្ធត្រូវប្រើផលប្រយោជន៍ជាតិ និងរបស់ប្រជាជន។ ប្រាក់ចំណូលបានមកពីពន្ធដារ ឬពន្ធគយត្រូវតែចូលទៅក្នុងបេឡារបស់រដ្ឋពោលគឺមិនមានចូលក្នុងហោប៉ៅរបស់បុគ្គលណាមួយនោះទេ។

លោក គង់ វិបុល អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារបាននិយាយថាកំណើនសេដ្ឋកិច្ច និងការវិនិយោគបានធ្វើឱ្យការប្រមូលចំណូលពន្ធអាកររបស់អគ្គនាយកដ្ឋានពន្ធដារបន្តកើនឡើងជារៀងរាល់ឆ្នាំ។

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

តាមការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយលើការអនុវត្តជាក់ស្តែង គឺជាការវិភាគដែលសារៈសំខាន់បំផុតក្នុងការវាយតម្លៃ វាស់វែងពីដំណើការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារដើម្បីឱ្យដឹងពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ខ្លួន ហើយនិងចេះកែប្រែចំណុចខ្សោយឱ្យទៅជាចំណុចខ្លាំងពេលនោះហើយប្រទេសជាតិនិងមានការរីកចម្រើនទៅមុខជានិច្ច។

## ៤.១ ការវិភាគលើចំណុចខ្លាំង

បន្ទាប់ពីបានធ្វើការស្រាវជ្រាវកន្លងមកទៅលើការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ ក្រុមនាងខ្ញុំបានវិភាគឃើញទៅលើចំណុចខ្លាំងមួយចំនួនមានដូចជា៖

- ការប្រមូលអាកររបស់អគ្គនាយកដ្ឋានពន្ធដារបានបង្កើតនូវប្រសិទ្ធភាពនៃប្រព័ន្ធរតនាគារជាតិ និងពង្រឹងវិស័យសារពើពន្ធ។
- ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារបានផ្តល់ប្រយោជន៍និងថវិកាថ្នាក់ក្រោមសម្រាប់បំភ្លឺសាធារណៈ។
- អគ្គនាយកដ្ឋានពន្ធដារមាននូវការកំណត់មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- អគ្គនាយកដ្ឋានពន្ធដារមានច្បាប់ស្តីពីការគ្រប់គ្រង និងប្រមូលអាករបំភ្លឺសាធារណៈច្បាស់លាស់ដែលមានអនុម័តដោយក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ។
- ការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ មានការកើនឡើងជាលំដាប់ដោយសារតែមូលហេតុមួយចំនួនដូចជាការពង្រឹងការអនុវត្ត វិធានការប្រមូលពន្ធប្រកបដោយតម្លាភាព និងប្រសិទ្ធភាពការរីកចម្រើននៃជីវភាពរបស់ប្រជាជនដែលធ្វើឱ្យការប្រើប្រាស់មានការកើនឡើង។
- អគ្គនាយកដ្ឋានពន្ធដារដែលតែងតែបង្កើតនូវសិក្ខាសាលាណែនាំ ដល់អ្នកជាប់ពន្ធទាំងអស់ឱ្យយល់ដឹងពីកាតព្វកិច្ចនិងសិទ្ធរបស់ពួកគេចំពោះរដ្ឋ ក៏ដូចជាចំណេះដឹងទាក់ទងនិងពន្ធដារដើម្បីធ្វើការបង់ប្រាក់និងដាក់លិខិតប្រកាសពន្ធឱ្យបានត្រឹមត្រូវ។
- អគ្គនាយកដ្ឋានពន្ធដារដែលតែងតែអនុវត្តនូវយុទ្ធសាស្រ្តរបស់ខ្លួន ក្នុងការផ្តល់ជាការបង្រៀនបន្ថែមដល់មន្រ្តីពន្ធដូចជាការផ្តល់សេវាកម្មពន្ធដារ និងការផ្តល់នូវភាពងាយស្រួលដល់អ្នកជាប់ពន្ធដែលតាមរយៈការធ្វើកំណែទម្រង់ពាក់ព័ន្ធ និងការធ្វើទំនើបកម្មបច្ចេកទេសវិទ្យាដែលរួមមានការបង្ហោះច្បាប់អនុក្រឹត្យប្រកាស និងព័ត៌មានផ្សេងៗទាក់ទងនិងពន្ធដារនៅលើគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ ការចុះបញ្ជី និងប្រកាសបង់ប្រាក់ពន្ធតាម Online ជាដើម។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ទន្ទឹមនិងភាពវិជ្ជមានដែលលើកឡើងខាងលើ តាមការវយៈការស្រាវជ្រាវរបស់ក្រុមនាងខ្ញុំក៏មើលឃើញពីកង្វះខាតមួយចំនួន ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមដើម្បីឱ្យការប្រមូលអាករបំភ្លឺសាធារណៈកាន់តែប្រសើរឡើងដូចជា៖

- នីតិវិធីនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានមិនមានភាពទូលំទូលាយដែលធ្វើឱ្យអ្នកជាប់ពន្ធមួយចំនួនមិនសប្បាយចិត្ត និងមិនសហការក្នុងភារកិច្ចនេះ។
- អគ្គនាយកដ្ឋានពន្ធដារមិនមាននូវផែនការ ឬគោលការណ៍សំខាន់ៗដើម្បីពន្យល់ ឬអប់រំទៅដល់អ្នកជាប់ពន្ធតាមមូលដ្ឋាននីមួយៗជាក់ស្តែង។
- អគ្គនាយកដ្ឋានមិនបានផ្តល់នូវព័ត៌មានច្បាស់លាស់អំពីតួនាទី និងភារកិច្ចរបស់អ្នកជាប់ពន្ធក្នុងការបង់ប្រាក់ពន្ធជូនពន្ធដារនៅឡើយ ដោយពួកគេគិតថាទឹកប្រាក់ដែលពួកគេបានបង់ជូនរដ្ឋមិនបានប្រយោជន៍អ្វីទេដល់ពួកគេ។
- ដំណើការនៃការបង់ប្រាក់ពន្ធនូវមានភាពយឺតយ៉ាវនៅឡើយដោយសារតែប្រតិបត្តិការនៃបង់ប្រាក់ពន្ធនូវមានភាពមិនច្បាស់លាស់ពីបែបបត់ និងវិធីសាស្ត្រនៃការគណនានៅឡើយ។
- ការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិ និងសេវានានារបស់អគ្គនាយកដ្ឋានពន្ធដារទៅកាន់សាធារណៈជនមិនមានភាពទូលំទូលាយ។
- ចំណូលដែលអគ្គនាយកដ្ឋានពន្ធដារបានប្រមូលមកពីអាករបំភ្លឺសាធារណៈ គឺទុកសម្រាប់ចំណាយទៅលើការបំភ្លឺភ្លើងសាធារណៈទៅតាមខេត្ត-ក្រុង ប៉ុន្តែនៅតាមទីជនបទដាច់ស្រយាលមិនមានការបំភ្លឺភ្លើងសាធារណៈទេ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវកន្លងមកនេះ ក្រុមរបស់នាងខ្ញុំបាន សង្កេតឃើញថាការប្រមូលពន្ធអាកររបស់អគ្គនាយកដ្ឋានពន្ធដារមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ភាពរីកចម្រើនលូតលាស់ទាំងអស់នេះហើយដែលជាផ្នែកមួយជួយដល់ប្រទេសជាតិដែលបានមកពីការបង់ពន្ធរបស់ប្រជាពលរដ្ឋ លើសពីនេះយើងក៏ឃើញដែរថាមានការកើនឡើងច្រើននៃចំនួនអ្នកជាប់ជាបន្តបន្ទាប់ ដែលអាចជួយទ្រទ្រង់ដល់ការផ្គត់ផ្គង់ចំណាយផ្សេងៗដែលស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ រួមទាំងការបំភ្លឺសាធារណៈទូទាំងប្រទេសកម្ពុជាដែលជួយឱ្យមានតម្លាភាព និងប្រសិទ្ធភាពនៃការរីកចម្រើនជីវភាពរបស់ប្រជាជន។ ទន្ទឹមនិងភាពវិជ្ជមានដែលបានលើកឡើងខាងលើនេះ តាមការស្រាវជ្រាវក្រុមនាងខ្ញុំក៏មើលឃើញថាកង្វះខាតមួយចំនួន តម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមដើម្បីឱ្យការប្រមូលកាន់តែប្រសើរឡើងគឺអ្នកជាប់ពន្ធនូវតែមិនទាន់យល់ច្បាស់ពី ការបង់ពន្ធដែលធ្វើឱ្យពួកគេគិតថាមិនទទួលបាននូវប្រយោជន៍អ្វីសោះដល់ពួកគេមួយវិញទៀតច្បាប់នៃការបង់ពន្ធមានភាពធូរលុង ដំណើរការបង់ពន្ធនូវតែមានភាពយឺតយ៉ាវដោយសាតែប្រតិបត្តិការមួយចំនួនមិនច្បាស់លាស់ បែបបទនិតិវិធីមួយចំនួននៃការបង់សាច់ប្រាក់ដែលធ្វើឱ្យអ្នកជាប់ពន្ធត្រូវចំណាយពេលវេលាច្រើនក្នុងដំណើរការដាក់លិខិតប្រការឱ្យបានត្រឹមត្រូវ។

សរុបជារួម ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈបានផ្តល់ប្រយោជន៍ជាច្រើនដល់សង្គមជាតិ បើទោះបីជា ប្រជាជនមិនទាន់យល់ដឹងច្បាស់ពីការបង់ពន្ធក៏ដោយក៏ពួកគេនូវតែបំពេញកាតព្វកិច្ចរបស់ពួកគេក្នុងការបង់ពន្ធដើម្បីទ្រទ្រង់សេដ្ឋកិច្ចនិងអភិវឌ្ឍន៍ប្រទេសជាតិឱ្យកាន់តែរីកចម្រើនដែលធ្វើឱ្យរាជរដ្ឋាភិបាលមានចំណូលគ្រប់គ្រាន់ក្នុងការចំណាយផ្សេងៗដែលស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ។

## ៥.២ ការផ្តល់អនុសាសន៍

យោងតាមការសន្និដ្ឋានខាងលើរួចមក ក្រុមរបស់នាងខ្ញុំបានសង្កេតឃើញថា អគ្គនាយកដ្ឋានពន្ធដារបានរៀបចំយុទ្ធសាស្ត្រដ៏ល្អ នៃការប្រមូលចំណូលយ៉ាងមានប្រសិទ្ធភាព រួមទាំងការយល់ដឹងនូវចំណេះដឹងនិងផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធតាមរយៈការវិវត្តន៍នូវបច្ចេកវិទ្យាថ្មីៗដែលមានលេខគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ។ ក្រុមរបស់នាងខ្ញុំ សូមបង្ហាញនូវភាពគាំទ្រ និងលើកទឹកចិត្តដល់អគ្គនាយកដ្ឋានពន្ធដារក្នុងការបន្តបេសកកម្ម ឬសកម្មភាពរបស់ខ្លួនក្នុងការអភិវឌ្ឍន៍នូវវិធីសាស្ត្រ និងបច្ចេកវិទ្យាថ្មីៗនិងពង្រឹងនិតិវិធីនេះឱ្យកាន់តែមានភាពប្រសើរឡើងបន្ថែមទៀត។ ទន្ទឹមនឹងនេះផងដែរអគ្គនាយកដ្ឋានពន្ធដារគួរតែកែលម្អនូវចំណុចខ្វះខាតខ្លះៗដូចខាងក្រោម៖

- អគ្គនាយកដ្ឋានពន្ធដារគួរតែបន្ត និងបន្ថែមការផ្សព្វផ្សាយអំពីនីតិវិធីការប្រមូលអាករបំភ្លឺសាធារណៈឱ្យកាន់តែទូលំទូលាយជូនអ្នកជាប់ពន្ធក៏ដូចជាប្រជាពលរដ្ឋទូទៅដើម្បីឱ្យពួកគាត់យល់ដឹងកាន់តែច្បាស់អំពីការរៀបចំសំណុំឯកសារសម្រាប់ប្រកាសពន្ធឱ្យបានឆាប់រហ័ស និងមានភាពងាយស្រួល។

- ចំពោះប្រភេទពន្ធណាមួយដែលរដ្ឋបាលសារពើពន្ធកំណត់ថា គួរចុះធ្វើការពន្យល់ណែនាំនោះ មន្ត្រីពន្ធដារនូវតាមមូលដ្ឋាន ត្រូវចុះអប់រំដល់អ្នកជាប់ពន្ធឱ្យបានយល់អំពីកាតព្វកិច្ចនិងសិទ្ធិរបស់អ្នកជាប់ពន្ធទាំងនោះ។
- អគ្គនាយកដ្ឋានពន្ធដារគួរតែពន្យល់និងផ្តល់ព័ត៌មានឱ្យបានច្បាស់លាស់អំពីតួនាទី និងភារកិច្ចរបស់អ្នកជាប់ពន្ធក្នុងការបង់ប្រាក់ពន្ធជូនរដ្ឋព្រោះរាល់ការបង់ប្រាក់ពន្ធទាំងអស់នោះជាប្រភពចំណូលដ៏សំខាន់ដែលរដ្ឋយកទៅបំភ្លឺទីសាធារណៈ។
- អគ្គនាយកដ្ឋានពន្ធដារគួរតែធ្វើសិក្ខាសាលាឱ្យបានច្រើនដើម្បីផ្តល់ចំណេះដឹងដល់អ្នកជាប់ពន្ធឬសហគ្រាសឱ្យបានយល់ច្បាស់អំពីដំណើរការនៃការបង់ពន្ធ និងវិធីសាស្ត្រនៃការគណនាពន្ធឱ្យបានត្រឹមត្រូវជូនរដ្ឋ។
- អគ្គនាយកដ្ឋានពន្ធដារគួរតែធ្វើការផ្សព្វផ្សាយអំពីច្បាប់ បទប្បញ្ញត្តិ និងសេវានានាឱ្យកាន់តែច្បាស់លាស់និងទូលំទូលាយទៅកាន់សាធារណៈជនទាំងអស់តាមប្រព័ន្ធអនឡាញ និងមធ្យោបាយផ្សេងៗដែលងាយស្រួលដល់អ្នកជាប់ពន្ធ។
- រាល់ចំណូលដែលប្រមូលបានពីអាករបំភ្លឺសាធារណៈអគ្គនាយកដ្ឋានពន្ធដារគួរតែបន្ថែមការដាក់ភ្លើងបំភ្លឺនៅតាមទីជនបទដាច់ស្រយាលដើម្បីផ្តល់ភាពស្រួលដល់សាធារណៈជន

# ឯកសារយោង


- ស្រ៊ាន់ គឹមស្រៀង, ផា មុី, ពិន គឹមស្រឿន, ដោក ស្រីរីន, ហ៊ិន មិថុនា.(២០២៣).*ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ.*សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់២០ វិទ្យាស្ថាន វ៉ាន់ដា.ទំព័រទី៤ដល់ទី៥.ភ្នំពេញ
- ស្រ៊ាន់ គឹមស្រៀង, ផា មុី, ពិន គឹមស្រឿន, ដោក ស្រីរីន, ហ៊ិន មិថុនា.(២០២៣).*ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ.*សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់២០ វិទ្យាស្ថាន វ៉ាន់ដា.ទំព័រទី១៤.ភ្នំពេញ
- ស្រ៊ាន់ គឹមស្រៀង, ផា មុី, ពិន គឹមស្រឿន, ដោក ស្រីរីន, ហ៊ិន មិថុនា.(២០២៣).*ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ.*សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់២០ វិទ្យាស្ថាន វ៉ាន់ដា ប្រវត្តិនៃពន្ធទំព័រ១៤និងទំព័រទី១៥.ភ្នំពេញ
- ស្រ៊ាន់ គឹមស្រៀង, ផា មុី, ពិន គឹមស្រឿន, ដោក ស្រីរីន, ហ៊ិន មិថុនា.(២០២៣).*ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ.*សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់២០ វិទ្យាស្ថាន វ៉ាន់ដា ទំព័រ១៥ដល់១៧.ភ្នំពេញ
- ស្រ៊ាន់ គឹមស្រៀង, ផា មុី, ពិន គឹមស្រឿន, ដោក ស្រីរីន, ហ៊ិន មិថុនា.(២០២៣).*ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ.*សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់២០ វិទ្យាស្ថាន វ៉ាន់ដាទំព័រ០៤និង០៦.ភ្នំពេញ
- ស្រ៊ាន់ គឹមស្រៀង, ផា មុី, ពិន គឹមស្រឿន, ដោក ស្រីរីន, ហ៊ិន មិថុនា.(២០២៣). *ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ.*សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់២០ វិទ្យាស្ថាន វ៉ាន់ដា.ទំព័រ០៦.ភ្នំពេញ
- ស្រ៊ាន់ គឹមស្រៀង, ផា មុី, ពិន គឹមស្រឿន, ដោក ស្រីរីន, ហ៊ិន មិថុនា.(២០២៣). *ដំណើរការនៃការប្រមូលអាករបំភ្លឺសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ.*សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាញគណនេយ្យ ជំនាន់២០ វិទ្យាស្ថាន វ៉ាន់ដា ទំព័រ០៦.ភ្នំពេញ
- សង្កប្ប. (ឆ្នាំ2023). *អគ្គនាយកដ្ឋាន.* Retrieved February, 02 2025, from https://www.sangapac.com/dictionary/a/6752
- KHsearch. ពន្ធ. (2020, January 21).*និយមន័យមូលដ្ឋានគិតពន្ធ.* Retrieved February, 02 2025, from https://www.khsearch.com/qna/28561
- KHsearch. ពន្ធ. (2020, March 10). *និយមន័យមូលដ្ឋានគិតពន្ធ.* Retrieved February, 02 2025, from https://www.khsearch.com/qna/30072
- FaceBook Page. HRTS Consulting. (2024, October 18). *ការគ្រប់គ្រង.* Retrieved February, 05 2025, from https://www.facebook.com/share/p/15CVvfriUi/
- KHsearch. General Knowledge. (2017, July 01). *ការគ្រប់គ្រង.* Retrieved February, 05 2025, from https://www.khsearch.com/qna/24
- SCRIBD. ជុំ សមវាសនា, ផាន់ ចាន់ពៅ, ឈួន ត្រាយ. (ឆ្នាំ២០២៥). *ការគ្រប់គ្រង.* Retrieved February, 05 2025, from https://www.scribd.com/document/475342687/%25E1%259E%25
- Clubniset. មិត្តនិស្សិត. (2011, May 31). *ការគ្រប់គ្រង.* Retrieved February, 07 2025, from https://clubniset.wordpress.com/2011/05/31/%E1%9E%93%E1

- Property Area. សុជារី. (2011, October 25). *និយមន័យអាករ*. Retrieved February, 07 2025, from https://propertyarea.asia/archives/84407
- Kh search. គ្រប់គ្រង. (2019, May 09). *ប្រវត្តិនៃការគ្រប់គ្រង*. Retrieved February, 10 2025, from https://www.khsearch.com/qna/24819
- បណ្ណាល័យអ្នក. Kong Chhayleng. (2020, July 26). *ទ្រឹស្តីពាក់ព័ន្ធនៃការគ្រប់គ្រង*. Retrieved February, 10 2025, from https://www.facebook.com/banalaineak/posts/84-modern-theory-of-management/167329684831908/

# ឧបសម្ព័ន្ធ







| ឆ្នាំ | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 | 2020 | 2021 | 2022 | 2023 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចំណូល(ប៊ីលានរៀល) | 2,360.05 | 2,962.13 | 3,525.48 | 4,251.16 | 5,196.80 | 5,988.71 | 7,754.81 | 8,791.40 | 11,277.32 | 11,700.52 | 11,266.79 | 13,993.20 | 14,629.10 |
| ចំណូល(លានដុល្លារ) | $590.01 | $731.39 | $870.49 | $1,049.67 | $1,283.16 | $1,478.69 | $1,914.77 | $2,197.85 | $2,819.33 | $2,869.02 | $2,781.92 | $3,455.11 | $3,612.12 |
| ផែនការ(ប៊ីលានរៀល) | 2,655.37 | 2,944.43 | 3,463.61 | 3,975.16 | 4,659.50 | 5,686.26 | 6,863.30 | 7,693.50 | 9,153.63 | 11,543.31 | 9,084.42 | 11,419.13 | 14,465.39 |
| ផែនការ(លានដុល្លារ) | $663.84 | $736.11 | $865.90 | $993.79 | $1,164.88 | $1,421.56 | $1,715.83 | $1,923.38 | $2,288.41 | $2,850.20 | $2,243.07 | $2,819.54 | $3,571.70 |
| %ភាគរយនៃចំណូល | 88.88% | 100.60% | 101.80% | 106.94% | 111.53% | 105.32% | 113.00% | 114.27% | 123.20% | 101.36% | 124.02% | 122.54% | 101.13% |

## ១-ទស្សនទាននៃចំណូលពន្ធផ្ទៃក្នុង

### ភាពខុសគ្នានៃកត្តាគន្លឹះសំខាន់ៗសម្រាប់ការប្រមូលពន្ធ រវាងប្រទេសអភិវឌ្ឍន៍ និងកម្ពុជា

| ល.រ | បរិយាយ | ប្រទេសអភិវឌ្ឍន៍ | ប្រទេសកម្ពុជា |
|---|---|---|---|
| ១ | ធនធានមនុស្ស | មានចំនួនច្រើន និង គុណភាពខ្ពស់ | មានចំនួនតិច និង គុណភាពមានកម្រិត |
| ២ | កម្រិតអនុលោមភាពសារពើពន្ធរបស់អ្នកជាប់ពន្ធ | ខ្ពស់ (អូស្រាលី/ស៊ុយអែត៖ លើសពី ៩៥%) | ទាប |
| ៣ | ផ្នត់គំនិតនិងវប្បធម៌បង់ពន្ធ | កម្រិតខ្ពស់ | មានកម្រិត |
| ៤ | សមត្ថភាពក្នុងការកំណត់ហានិភ័យ | មានកម្រិតខ្ពស់ | មានកម្រិត |
| ៥ | កម្រិតនៃការគេចវេះពន្ធ | មានកម្រិតទាប | មានកម្រិតខ្ពស់ |
| ៦ | ប្រព័ន្ធពន្ធដារ | អភិវឌ្ឍល្អ | កំពុងកែទម្រង់ |
| ៧ | សិទ្ធិអំណាចរបស់រដ្ឋបាលសារពើពន្ធ | មានសិទ្ធិអំណាចទូលំទូលាយ | កំពុងពង្រឹង |
| ៨ | បច្ចេកវិទ្យាព័ត៌មាន និងហេដ្ឋារចនា-សម្ព័ន្ធគាំទ្រ ( IT & Infrastructure ) | មានកម្រិតខ្ពស់ | បាននិងកំពុងបន្តអភិវឌ្ឍ |

## ២- គោលការណ៍រួមនៃកំណែទម្រង់ប្រព័ន្ធពន្ធដារ(២០១៩-២០២៣)

**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤**
(Rectangular Strategy Phase4)

**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
(PFMRP)

**យុទ្ធសាស្ត្រគៀររចំណូល ២០១៩-២០២៣**
(RMS)

**ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ២០១៩-២០២៣ របស់អគ្គនាយកដ្ឋានពន្ធដារ**
(SP & OP)



**អភិបាលកិច្ចល្អ**
(Good Governance)

**រដ្ឋបាលកិច្ចល្អ**
(Good Administration)

**ប្រសិទ្ធិភាពនៃភាពជាអ្នកដឹកនាំ**
(Effective Leadership & Management)

**គុណធិបតេយ្យ**
(Meritocracy)

<u>គោលបំណងជាយុទ្ធសាស្ត្រ៖</u>

- **គោលបំណងទី១៖** បង្កើនអនុលោមភាពតាមច្បាប់ដោយស្ម័គ្រចិត្ត និងកាត់បន្ថយជាអតិបរមានូវបន្ទុកអ្នកជាប់ពន្ធ ដោយផ្តល់សេវាប្រកបដោយគុណភាព
- **គោលបំណងទី២៖**បន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រកបដោយភាពទន់ភ្លន់ ម៉ឺងម៉ាត់ និងស្មើភាព ដើម្បីជំរុញអ្នកជាប់ពន្ធ ឱ្យបំពេញកាតព្វកិច្ចសារពើពន្ធបានត្រឹមត្រូវ
- **គោលបំណងទី៣៖** អនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយពង្រឹងស្ថាប័ន

## ២- គោលការណ៍រួមនៃកំណែទម្រង់ប្រព័ន្ធពន្ធដារ

### គំរូនៃការពង្រឹងអភិបាលកិច្ចល្អនៃអគ្គនាយកដ្ឋានពន្ធដារ




កាលមុន

បច្ចុប្បន្ន



## ៣- លទ្ធផលនៃកំណែទម្រង់គោលនយោបាយ និងរដ្ឋបាលសារពើពន្ធ

### កំណែទម្រង់រចនាសម្ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  - អគ្គនាយកដ្ឋានពន្ធដារ
    - អគ្គនាយក
      - អគ្គនាយករង
      - នាយកដ្ឋាន
      - សាខាពន្ធដារខណ្ឌ — សាខាពន្ធដារខណ្ឌចំនួន ០៩
      - សាខាពន្ធដារខេត្ត — សាខាពន្ធដារខេត្តចំនួន ២៤

អាជ្ញាធរមានសមត្ថកិច្ចក្នុងការពិនិត្យនិងតាមដានការអនុវត្តច្បាប់លើ អពដ រួមមាន៖

-អាជ្ញាធរសវនកម្មជាតិ
-អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃ កសហវ
-អគ្គាធិការដ្ឋាន នៃ កសហវ
-អង្គភាពប្រឆាំអំពើពុករលួយ

1) ន.រដ្ឋបាល និងកិច្ចការទូទៅ
2) ន.ហិរញ្ញវត្ថុ និងបុគ្គលិក
3) ន.នីតិកម្ម គោលនយោបាយសារពើពន្ធ
4) ន.ពន្ធចលនទ្រព្យ និងអចលនទ្រព្យ
5) ន.បច្ចេកវិទ្យាព័ត៌មាន
6) ន.ស៊ើបអង្កេតបទល្មើសពន្ធដារ
7) ន.គ្រប់គ្រងអ្នកជាប់ពន្ធធំ
8) ន.គ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
9) ន.សវនកម្មសហគ្រាស
10) សាលាពន្ធដារជាតិ
11) ទីចាត់ការពន្ធដាររាជធានីភ្នំពេញ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..១២៥.....សហវ.ប្រក.

# ប្រកាស
# ស្ដីពី
# អាករសម្រាប់បំភ្លឺសាធារណៈ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៦ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីអាករសម្រាប់បំភ្លឺសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ១ .-**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការផ្គត់ផ្គង់ផលិតផលសុរា មេរ៉ៃ ឬថ្នាំជក់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .-**

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- ផលិតផលជាប់អាករ សំដៅដល់ សុរា មេរ៉ៃ ឬថ្នាំជក់។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ៖

ក- សុរា សំដៅដល់ ផលិតផលគ្រប់ប្រភេទដែលមានជាតិអាល់កុល លើកលែងតែផលិតផលអាល់កុលដែលប្រើក្នុងវិស័យវេជ្ជសាស្ត្រ។

ខ- មេរ៉ៃ សំដៅដល់ ទឹកស្រវឹងដែលធ្វើឡើងដោយការត្រាំគ្រឿងផ្សំផ្សេងៗ មានជាអាទិ៍ ស្រាបៀរ ឬភេសជ្ជៈមានជាតិស្រវឹង លើកលែងតែទឹកត្នោតជូរ និងស្រាស ដែលផលិតដោយមិនមានការកែច្នៃរក្សាគុណភាព និង/ឬវេចខ្ចប់ តាមរូបភាពសិប្បកម្ម ឬឧស្សាហកម្ម។

គ- ថ្នាំជក់ សំដៅដល់ផលិតផលទាំងមូលឬមួយផ្នែកដែលផ្សំឡើងដោយស្លឹកថ្នាំជក់ ឬសារធាតុថ្នាំជក់ ឬសារធាតុផ្សេងៗទៀតជាវត្ថុធាតុដើម ដែលផលិតសម្រាប់យកទៅជក់ មានជាអាទិ៍ បារី បារីស៊ីហ្គា និងបារីអេឡិចត្រូនិកគ្រប់ប្រភេទ។

២-អាករ សំដៅដល់ អាករសម្រាប់បំភ្លឺសាធារណៈ។

៣-បុគ្គលជាប់អាករ សំដៅដល់ អ្នកផលិត ឬអ្នកនាំចូលផលិតផលជាប់អាករ ហើយធ្វើការផ្គត់ផ្គង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្រាប់គោលដៅនៃកថាខណ្ឌនេះ៖

ក- អ្នកផលិត សំដៅដល់ ម្ចាស់ផលិតផលដែលផលិតផលិតផលជាប់អាករដោយខ្លួនឯង ឬដែលជួលបុគ្គលដទៃទៀតឱ្យផលិតផលិតផលជាប់អាករឱ្យខ្លួន។

ខ- អ្នកនាំចូល សំដៅដល់ ម្ចាស់ផលិតផលដែលនាំចូលផលិតផលជាប់អាករដោយខ្លួនឯង ឬដែលប្រគល់សិទ្ធិឱ្យបុគ្គលដទៃទៀតនាំចូលផលិតផលជាប់អាករឱ្យខ្លួន។

**ប្រការ៤ .-**

អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវកំណត់តាមអត្រា ៥ (ប្រាំ) ភាគរយ នៃមូលដ្ឋានគិតអាករ។

**ប្រការ៥ .-**

មូលដ្ឋានគិតអាករសម្រាប់បំភ្លឺសាធារណៈ គឺជាថ្លៃផ្គត់ផ្គង់កត់ត្រាលើវិក្កយបត្ររួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម និងអាករសម្រាប់បំភ្លឺសាធារណៈខ្លួនឯង។

**ប្រការ៦ .-**

១- អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវដល់កំណត់និងត្រូវបង់តែម្តងគត់នៅពេលផ្គត់ផ្គង់ផលិតផលជាប់អាករដំបូងបន្ទាប់ពីផលិត ឬនាំចូលក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ការផ្គត់ផ្គង់ផលិតផលជាប់អាករ ដែលកែច្នៃពីផលិតផលដែលបានបង់អាករសម្រាប់បំភ្លឺសាធារណៈរួចហើយ ត្រូវចាត់ទុកថាជាការផ្គត់ផ្គង់ដំបូងបន្ទាប់ពីផលិត។

៣-វិធាននៃការផ្គត់ផ្គង់ ត្រូវអនុវត្តស្របតាមវិធាននៃការផ្គត់ផ្គង់សម្រាប់អាករលើតម្លៃបន្ថែម ដូចមានចែងក្នុងកថាខណ្ឌទី១ ដល់កថាខណ្ឌទី៤ នៃមាត្រា៦១ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ៧ ._**

១- បុគ្គលជាប់អាករត្រូវតែជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

២- អ្នកទទួលសិទ្ធិផលិត ឬនាំចូលផលិតផលជាប់អាករឱ្យបុគ្គលជាប់អាករ ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

ក- ផ្តល់ព័ត៌មានមកអគ្គនាយកដ្ឋានពន្ធដារដោយភ្ជាប់មកជាមួយនូវលិខិតប្រគល់សិទ្ធិ កិច្ចសន្យាផលិត ឬនាំចូល ជាមួយបុគ្គលជាប់អាករ មុនពេលធ្វើការផលិត ឬនាំចូលផលិតផលជាប់អាករ។

ខ- បញ្ឈប់ការផលិត ឬនាំចូលផលិតផលជាប់អាករ នៅពេលទទួលបាននូវការជូនដំណឹងពីអគ្គនាយកដ្ឋានពន្ធដារស្តីពីការមិនបានបំពេញកាតព្វកិច្ចត្រឹមត្រូវរបស់បុគ្គលជាប់អាករ។

គ- ត្រូវបានចាត់ទុកជាបុគ្គលជាប់អាករ និងទទួលខុសត្រូវបង់ប្រាក់អាករស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ក្នុងករណីមិនបានបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុងវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះ។

**ប្រការ៨ ._**

បុគ្គលជាប់អាករ ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់អាករសម្រាប់បំភ្លឺសាធារណៈ ជារៀងរាល់ខែយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលផលិតផលត្រូវបានផ្គត់ផ្គង់។

**ប្រការ៩ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ ._**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤ តទៅ។

ថ្ងៃ [illegible] ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ១០ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ